ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

* ចំណងមិត្តភាពនិងការឱបក្តប់គ្នាទៅវិញទៅមក
* ការពង្រឹងនិងពង្រីកចំណេះដឹង និង វិជ្ជាជីវៈ
* ការពារផលប្រយោជន៍គ្នាទាំងផ្លូវចិត្ត ~ សំភារៈ

២០

# ទស្សនាវដ្ដី គ្រូបង្រៀន



Preah Vihear Temple

ខែ កក្កដា - សីហា - កញ្ញា ឆ្នាំ ២០០៤
ផ្សាយចេញរាល់ត្រីមាស ពីទីចាត់ការសមាគមបុគ្គលិកសិក្សាខ្មែរ
១២៨B មហាវិថីព្រះនរោត្តម (ភ្នំពេញ)

# មាតិកា


**គណៈកម្មការរៀបរៀង និង និពន្ធ**

- លោក កែវ យ៉ារ
- លោក ងុំ ហ៊ីន
- លោកស្រី គុយ ផល្លា
- លោក ស្វាយ ទិស្ស
- លោកជំទាវ ប៉ែន ណាវុល
- លោក ថោង បូរ៉ាន់
- លោក កៅ ជឿន
- លោកស្រី ប្រាក់ សូលីដា
- លោកស្រី ទន់ សុភ្ញុំ
- លោក ប៉ែន សារុន
- សមាជិក-សមាជិកា ស.ប.ស.ខ.

**គណៈកម្មការត្រួតពិនិត្យ**

- លោក យស់ អាង
- លោកជំទាវ ហួរ ស៊ីរី
- លោកបណ្ឌិត អ៊ុម កុច
- លោក ស៊ិន ស៊ីម
- លោក ស៊ុង ភ៉ន់ថន
- លោក សួង សារុន

**វិចិត្រករ**

លោក ចាន់ ត្រា

**ការីកុំព្យូទ័រ**

ក. ម៉ៃ សូនី

**គ្របខាងក្រៅ**

- ពីមុខ: ប្រាសាទព្រះវិហារ
- ពីក្រោយ: ព្រះបរមរាជវាំងនៅឆ្នាំ១៨៨៥



| ល.រ. | ចំណងជើងអត្ថបទ | ទំព័រ |
|---|---|---|
| ១ | វិចារណកថា | ១ |
| | **រាជកិច្ច** | |
| ២ | ការកែសំរួលរចនាសម្ព័ន្ធនាយកដ្ឋានបឋម និង មត្តេយ្យសិក្សា... | ២ |
| | **ចម្បងមីទូទៅ** | |
| ៣ | តំលៃនៃអំពើ | ៥ |
| ៤ | ការប្រៀបធៀបរបាំប្រពៃណីទៅនឹងរបាំប្រជាប្រិយ (ត) | ៧ |
| ៥ | ការគោរពច្បាប់ធម្មជាតិ និង ការត្រួតត្រាលើធម្មជាតិ | ១២ |
| | **ចិត្តវិទ្យា-អប់រំ** | |
| ៦ | ចិត្តរំភើប និង កំលាំងចិត្ត | ១៤ |
| ៧ | ដំណើរការអភិវឌ្ឍវិស័យអប់រំនៅសហរដ្ឋអាមេរិក (ត) | ១៧ |
| | **វិទ្យាសាស្ត្រ និង ពត៌មានវិទ្យា** | |
| ៨ | ថាមពលព្រះអាទិត្យ | ២១ |
| | **ការអប់រំ និង គរុកោសល្យ** | |
| ៩ | ករណីយកិច្ចគ្រូបង្រៀននៅក្រៅសាលារៀន | [illegible] |
| ១០ | កំណើតនៃការអប់រំសីលធម៌ (ត) | [illegible] |
| ១១ | ភាសា : សំនេរក្នុងសម័យទំនើបរូបនីយកម្ម | [illegible] |
| ១២ | គណិតវិទ្យា : វិធីបូក និង ដក | [illegible] |
| ១៣ | គណិតវិទ្យា : ចតុកោណ | [illegible] |
| ១៤ | គំនូរ : វិធីបង្រៀនគំនូរ (ត) | [illegible] |
| | **ភាពីគំនាញ និង គំសាន្ត** | |
| ១៥ | វិធីវាស់ស្រមោល ដើម្បីដឹងប្រវែងពិត | [illegible] |
| ១៦ | បណ្ដាំសង្វេគគីរី | [illegible] |
| | **វេទិកាស្វែងរក** | |
| ១៧ | គ្រាមភាសា | [illegible] |
| ១៨ | រង្វាស់ខ្មែរបុរាណ | [illegible] |
| | **ពត៌មាន** | |
| ១៩ | តើអ្នកគ្រូ លោកគ្រូដឹងដែរឬទេថា... | [illegible] |
| ២០ | វេទិកាស្ត្រី | [illegible] |

# វិចារណកថា

បច្ចុប្បន្ននេះ បច្ចេកទេសវិទ្យានៃគមនាគមន៍មានសំបូរបែបដូចជា កាសែត វិទ្យុ ទូរទស្សន៍ ទស្សនាវដ្ដី ពត៌មានវិទ្យា... ផ្សព្វផ្សាយគ្រប់ពេលវេលាពីក្នុងប្រទេស ពីក្រៅប្រទេស ធ្វើអោយពិភពលោកហាក់បីដូចស្ថិតនៅជិតគ្នាបង្កើយ ។ តែគមនាគមន៍ទាំងនោះ មានទាំងខ្លឹមសារពិតតាមព្រឹត្តិការណ៍ មានទាំងការពិចារណាលើព្រឹត្តិការណ៍ រឺធ្វើបដិសំយោគលើព្រឹត្តិការណ៍ទៅតាមទស្សនះផ្សេងៗតាមនិន្នាការលើពិភពលោក ។ ដូចនេះអ្នកទទួលពត៌មាន ត្រូវមានការវិភាគ និង ជ្រើសរើស ។ ក្នុងករណីនេះ ព្រះពុទ្ធអង្គទ្រង់លើកជាការពិចារណាមួយថា តើគួរយើងដាក់ជំនឿយ៉ាងដូចម្ដេច ទៅលើដំណឹងផ្សេងៗ ។ ជាព្រះយោបល់ ព្រះពុទ្ធអង្គទ្រង់ណែនាំហាមជឿដោយប្រាសចាកហេតុផលដូចប្រការខាងក្រោមនេះ ÷

១- ជឿដោយឮតៗគ្នា

២- ជឿតាមល្បីល្បាញ

៣- ជឿដោយផ្អែកទៅលើតម្រាក្បួនខ្នាត

៤- ជឿដោយគ្នាន់គ្នេរគិតប៉ាន់ស្មានដោយខ្លួនឯង

៥- ជឿដោយសំអាងថាស្របគំនិត រឺ សមតាមគំហើញរបស់ខ្លួន

៦- ជឿដោយអាង រឺឃើញថា អ្នកផ្ដល់យោបល់ធ្លាប់មានកេរ្តិ៍ឈ្មោះគួរអោយជឿបាន

៧- ជឿដោយរាប់អានថា អ្នកនេះជាគ្រូរបស់ខ្លួន ។

**គណៈកម្មាធិការនាយក**

# រាជកិច្ច

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ១០៤ អនក្រ.បក**

# អនុក្រឹត្យ
## ស្ដីពី
## ការកែសំរួលរចនាសម្ព័ន្ធនាយកដ្ឋានបឋម និង មត្តេយ្យសិក្សា ជានាយកដ្ឋានបឋមសិក្សា និង នាយកដ្ឋានអប់រំកុមារតូច
## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦-០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

## សំរេច

**<u>មាត្រា១</u>**

ត្រូវបានកែសំរួលរចនាសម្ព័ន្ធនាយកដ្ឋានបឋម និង មត្តេយ្យសិក្សាជា ពីរ នាយកដ្ឋាន គឺនាយកដ្ឋាន

បឋមសិក្សា និង នាយកដ្ឋានអប់រំកុមារតូច ចំណុះអគ្គនាយកដ្ឋានអប់រំនៃក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា២**

នាយកដ្ឋាននីមួយៗ មានមុខងារ និង ភារកិច្ចដូចខាងក្រោម :

**ក- នាយកដ្ឋានបឋមសិក្សា**

- អភិវឌ្ឍអប់រំបឋមសិក្សាសំរាប់ការអប់រំសំរាប់ទាំងអស់គ្នា
- លើកទិសដៅកសាងផែនការអភិវឌ្ឍអប់រំបឋមសិក្សារយៈពេលវែង មធ្យម ខ្លី
- កែលំអការអប់រំបឋមសិក្សា ដើម្បីធានាការចូលរៀនប្រកបដោយសមធម៌ និង គុណភាពអប់រំប្រកបដោយប្រសិទ្ធភាព
- កសាងគោលនយោបាយ គោលការណ៍ លិខិតបទដ្ឋានផ្សេងៗ ដើម្បីគ្រប់គ្រង និង អភិវឌ្ឍការអប់រំបឋមសិក្សា
- គ្រប់គ្រង និង ត្រួតពិនិត្យដំណើរការសិក្សានៅគ្រប់គ្រឹះស្ថានបឋមសិក្សារដ្ឋ និង ឯកជនលើការងាររដ្ឋបាល និង បច្ចេកទេស
- តាមដានត្រួតពិនិត្យ និង កែលំអការអនុវត្តកម្មវិធីសិក្សា បច្ចេកទេសគរុកោសល្យ
- សិក្សាសំណើសុំបង្កើត បើក និង ទទួលស្គាល់សាលាបឋមសិក្សារដ្ឋ និង ឯកជន និង សំណើបង្រៀនថ្នាក់ពីរពេល ថ្នាក់គួប

**ខ- នាយកដ្ឋានអប់រំកុមារតូច**

- អភិវឌ្ឍអប់រំកុមារតូច (០-៦ឆ្នាំ) សំរាប់ការអប់រំសំរាប់ទាំងអស់គ្នា
- លើកទិសដៅកសាងផែនការអភិវឌ្ឍអប់រំកុមារតូច រយៈពេលវែង មធ្យម ខ្លី ដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ និង សហគមន៍
- កសាងគោលនយោបាយ គោលការណ៍ លិខិតបទដ្ឋានផ្សេងៗ ដើម្បីគ្រប់គ្រង និង អភិវឌ្ឍវិស័យអប់រំកុមារតូច
- គ្រប់គ្រង និង ត្រួតពិនិត្យថ្នាក់ និង សាលាមត្តេយ្យសិក្សាទាំងរដ្ឋ និង ឯកជនលើការងាររដ្ឋបាល និង បច្ចេកទេស
- ជំរុញការអភិវឌ្ឍមត្តេយ្យសហគមន៍ ទារកដ្ឋាន និង ជំរុញគោលការណ៍អប់រំសហគមន៍ (ម្តាយ) ដើម្បីធានាថែទាំកុមារ ទាំងសុខភាព ទាំងបញ្ញា ដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ និង សហគមន៍
- តាមដានត្រួតពិនិត្យ និង កែលំអ ការអនុវត្តកម្មវិធីសិក្សា បច្ចេកទេសគរុកោសល្យ
- សិក្សាសំណើសុំបង្កើត បើក និង ទទួលស្គាល់សាលាមត្តេយ្យសិក្សារដ្ឋ និង ឯកជន និង សំណើផ្សេងៗពាក់ព័ន្ធមត្តេយ្យសិក្សា និង ទារកដ្ឋាន

**មាត្រា ៣**

នាយកដ្ឋានបឋមសិក្សា និង នាយកដ្ឋានអប់រំកុមារតូច ត្រូវដឹកនាំដោយប្រធានមួយរូប និង អនុប្រធានជាជំនួយការមួយរូប រឺច្រើនរូបតាមការចាំបាច់ ។

**មាត្រា ៤**

ភារកិច្ចជាក់ស្តែង និង រចនាសម្ព័ន្ធរបស់នាយកដ្ឋានបឋមសិក្សា និង នាយកដ្ឋានអប់រំកុមារតូច ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៥**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវបានចាត់ទុកជានិរាករណ៍ ។

**មាត្រា ៦**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

លេខ ៣១ អយក.ចម

បានថតចំលងត្រឹមត្រូវតាមច្បាប់ដើម

បញ្ជូនមកនាយកដ្ឋានក្រោមឪវាទក្រសួង -មន្ទីរអប់រំ

យុវជន និង កីឡាគ្រប់ខេត្ត -ក្រុង "ដើម្បីជ្រាបជាពត៌មាន"

ភ្នំពេញ, ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០២

**តប.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

**អគ្គនាយក**

**ឌយ អូន**




# តម្លៃនៃអំពើ

មនុស្សតែងត្រេកត្រអាលទៅលើមាស ពេជ្រ ក៏ព្រោះតែវាមានលក្ខណៈសំខាន់ដែលគេប្រាថ្នា រឺដែលជាទីគួរចង់បាន នោះគឺតំលៃរបស់វា ។ ចុះចំពោះខ្លួនឯងវិញ តើប្រាថ្នាចង់បានអ្វីដែរ ? ។

"សប្បាយចិត្តណាស់ ពេញចិត្តណាស់ តែប៉ុននេះដេកលក់ហើយ មានសង្ឃឹមហើយ កុសលខ្ញុំហើយ ឬ លំបាកចិត្តណាស់ អស់សង្ឃឹមរលីង អភ័ព្វអ្វីម្ល៉េះ? អកុសលអ្វីម្ល៉េះ? ធ្វើម្ដេចកម្មពៀរវេរា ហួសហើយជាតិនេះ នេះជាព្រហ្មលិខិត ។ល ។" ទាំងនេះ គឺជាការអោយតំលៃរបស់បុគ្គលម្នាក់ៗ ។ តំលៃទាំងនេះ បានឆ្លុះបញ្ចាំងនូវផលនៃអំពើមួយ ។ ជាក់ស្ដែង នៅពេលយើងសំរេចការងារលំបាកលំបិន គ្រោះថ្នាក់ដល់អាយុជីវិត យើងហាក់ដូចជារំភើប អណ្តែតខ្លួន ។

ដូចនេះអំពើមួយបង្កអោយផលមួយដែលមានលក្ខណៈសំខាន់ផ្ទាល់របស់វា ដែលគេចង់បានសំរាប់ខ្លួនឯងក៏ដូចជាសំរាប់អ្នកដទៃ ។ តំលៃនេះបានធ្វើអោយរាងកាយយើងមានការរំភើបត្រេកត្រអាល រឺការឈឺចាប់ រឺអោយ ចិត្តយើងកើតមានសេចក្ដីរីករាយ សោមនស្ស ក្ដីសង្ឃឹម សុភមង្គល នោះគឺកុសល រឺអោយចិត្តយើងកើតទុក្ខ ទោមនស្សអស់សង្ឃឹម នោះគឺអកុសល ។

អ្នកខិតខំព្យាយាមសិក្សាស្រាវជ្រាវ នោះនឹងទទួលចំណេះដឹង ចំណេះធ្វើ និង ឥរិយាបថសក្តិសមនឹងក្លាយទៅជាអរិយជន ។ លោក ផ្លា តុង (Platon) បានពោលថា : "កុសលពិតប្រាកដរបស់មនុស្ស គឺការបង្កើតអោយបានសំរេចនូវ "ខ្លឹម" របស់ខ្លួន ។ ទស្សនវិទូទាំងឡាយជាបុគ្គលប្រកបដោយ "ខ្លឹម" នៃជីវិតរបស់គេ ។

គេមិនអាចអោយតំលៃមនុស្សបានពិតប្រាកដ "សមុទ្រជ្រៅ តែចិត្តមនុស្សជ្រៅជាងទៅទៀត" ។ អំពើដែលគេប្រព្រឹត្តទៅហាក់ដូចជាអ្នកមានសប្បុរសធម៌បំផុត រឺជឿស៊ុបបំផុត តែខាងក្នុងវិញ យើងមិនអាចឆ្លុះបញ្ចាំងបានឡើយ ។ ឧទាហរណ៍ : ព្រះបច្ចេកពុទ្ធមួយអង្គត្រូវគេធ្វើគត់ដោយស្រាវជ្រាវរកឧក្រិដ្ឋជនមិនឃើញ តែធាតុពិត គឺការសុគតរបស់ព្រះបច្ចេកពុទ្ធ[១] នោះ គឺទាយិកាម្នាក់ដែលបានផ្ចិតផ្ចង់ ផ្គត់ផ្គង់ចង្ហាន់បិណ្ឌបាត្រជាទៀងទាត់រាប់ខែឆ្នាំមកហើយ ។

(១) លោកអ្នកត្រាស់ដឹងចំពោះបានតែខ្លួនមួយ សំដែងធម៌ប្រៀនប្រដៅអ្នកដទៃផងមិនកើត

ដូចនេះ មានតែបុគ្គលខ្លួនឯងទេដែលអោយតំលៃអំពើរបស់ខ្លួនបាន ហើយតើមាននរណាម្នាក់ដែលលើកបង្អាប់ខ្លួនឯង ។ ច្បាប់ពាក្យចាស់បានលើកឡើងថា "ស្មៀកស្បង់មិនកោរសក់ ឆ្នុះកញ្ចក់ធ្មេចនេត្រា", "ឃើញសេះថាជាលា ឃើញគជា[១] ថាកណ្ដុរ" ។ រីឯលោក ឡា ហ្វុងតែន (La Fontaine) បានកត់សំគាល់ឃើញថា មនុស្សប្រដាប់ដោយថង់ពីរ : ថង់ជាកុសលតែងបង្ហាញនៅពីមុខ ហើយថង់ជាអកុសលនៅពីខាងក្រោយខ្នង ហើយធ្ងន់កណ្ដុក ។ ភាពមិនស្មោះត្រង់ ភាពលាក់លៀមគ្នា ការធ្វើមិនអោយទុកចិត្តគ្នាបាន នេះជាហេតុធ្វើអោយមានការប្រឈមដាក់គ្នាជានិច្ច ។

ដូចនេះតំលៃពិតប្រាកដ គឺជាតំលៃដែលសហគមន៍បានផ្ដល់អោយ ហើយខ្លឹមនៃតំលៃមានលក្ខណៈជាសកល ។ ក្នុងការវាយតំលៃអំពើ យើងត្រូវមានជំហរដូចតទៅ ÷

- សំលឹងមើលបញ្ហាទាំងឡាយតាមទស្សនៈអ្នកដទៃ
- ប្រមាណការប្រព្រឹត្តអំពើរបស់ខ្លួនលើអ្នកដទៃ
- ប្រដូចខ្លួនទៅនឹងអ្នកដទៃ
- បង្កើតទស្សនៈទិតៀន និង ផលវិបាក
- ធ្វើការផ្ទៀងផ្ទាត់

ស្រីហិតោបទេស ទទួលស្គាល់បុគ្គលសក្តិសមជាបណ្ឌិត នោះគឺបុគ្គលឃើញរបស់អ្នកដទៃហាក់បីដូចជាដុំថ្ម ឃើញស្ត្រីទាំងឡាយហាក់ដូចជាម្ដាយរបស់ខ្លួន ។

លោក : កែវ យ៉ារ

ប្រភព : ទស្សនវិជ្ជា "ខេមរយានកម្មភាគ ២ និង ស្រីហិតោបទេស"

★★★★★★★

**គុណសម្បត្តិនៃមន្ត្រី**

- សតិ គឺការចាំបាន ១
- ការប៉ិនប្រសិទ្ធិវិនិច្ឆ័យហេតុផលក្នុងប្រយោជន៍ដ៏សំខាន់ ១
- ការដឹងប្រាកដ ១
- ការម៉ឺងម៉ាត់ ១
- ការចេះរក្សាប្រឹក្សាសំងាត់ ១

ស្រីហិតោបទេសភាគ ៤

(១) ដីរទាំងឡាយ

# ការប្រៀបធៀបរបាំប្រពៃណីទៅនឹងរបាំប្រជាប្រិយ(ត)

ដើម្បីកុំអោយភ័ន្តច្រឡំភាពដូចគ្នានៃរបាំប្រពៃណី និង របាំប្រជាប្រិយថាដូចគ្នា ឬចង់ហៅមួយណាក៏បានដូចគ្នានោះ យើងសាកល្បងពន្យល់បង្ហាញអ្នកអានសំរាប់ពិចារណាដូចខាងក្រោម ÷

## ១~ របាំប្រពៃណី

របាំប្រពៃណីជារបាំស្ដែងចេញឡើងរបស់ប្រជាជនទៅតាមជនបទ ព្រៃភ្នំក្រំថ្ម (ជនជាតិភាគតិច) របាំនេះច្រើនជាប់ទាក់ទងទៅនឹងទំនៀមទំលាប់របស់អ្នកស្រុកអ្នកភូមិដែលទំលាប់ធ្វើ ដើម្បីប្រារព្ធពិធីបួងសួងវត្ថុសក្ដិសិទ្ធិអោយអាណិតអាសូរ ឬសន្ដោសប្រណីដល់ការរស់នៅរបស់គេអោយជួបប្រទះភាពសំបូរសប្បាយ សុខសន្តិភាព ផុតពីឧបទ្រពចង្រៃផងទាំងពួង ។ មួយទៀត គឺជារបាំដែលមានទំនាក់ទំនងទៅនឹងជំនឿសាសនា ពិធីមង្គលការ រឿងនិទាន ដែលប្រជាជនបាននិទានត១ៗគ្នាពីសកម្មភាពរបស់សត្វព្រៃ ធម្មជាតិមួយចំនួនទៀតផង ។

### ការសំគាល់របាំប្រពៃណី

របាំប្រពៃណីមានលក្ខណៈដូចខាងក្រោម ÷

**ក. ពេលសំដែង**

- របាំប្រពៃណីពុំអាចសំដែងបានគ្រប់ពេល ឬទៅតាមការចូលចិត្ត នឹកឃើញ រួចសំដែងនោះទេ គឺមានពេលវេលាច្បាស់លាស់របស់វា ។
- របាំនេះ ត្រូវលើកយកមកសំដែងពេលមានពិធីបុណ្យធំៗរបស់ជាតិ ឬពិធីតាមជំនឿផ្សេងៗ ដូចជាចូលឆ្នាំ ឡើងអ្នកតាចាស់ស្រុកជាដើម ។

**ខ. ទីកន្លែង**

គេពុំអាចសំដែងតាមកន្លែងណាដែលនឹកឃើញ ឬទីណាក៏បាននោះទេ ពោលគឺសំដែងនៅទីកន្លែងដែលបានកំណត់ច្បាស់លាស់ ធ្លាប់ប្រកាន់យកជាយូរយារណាស់មកហើយ ។

**គ. បំណង**

គេពុំមែនលេងបំរើការសប្បាយធម្មតារបស់ប្រជាជនទេ ។ របាំនេះសំដែងសំរាប់អង្វរលន់តួ រណបផ្គាប់ផ្គុន បំពេរអារម្មណ៍ដល់អក្ខតដែលប្រជាជនយល់ថា ជាអ្នកខ្លាំងពូកែសក្ដិសិទ្ធិអាចជួយគេបានពេលគេជួបនូវវិបត្តិផ្សេងៗ ។

## ២~ របាំប្រជាប្រិយ

របាំប្រជាប្រិយ គឺរបាំដែលប្រជាជនស្រឡាញ់ចូលចិត្តគ្រប់ៗគ្នា ។ វាជារបាំបំរើដល់ការកំសាន្តសប្បាយរបស់ប្រជាជន ដើម្បីបន្ធូរបរិយាកាសអាប់អួរក្រោយពីការប្រកបអាជីវកម្ម ការធ្វើពលកម្មនឿយហត់ ឬក៏ពេលដែលគេអាចទទួលបានជោគជ័យលើការដែលគេបានធ្វើកន្លងមក ។

## ការសំដែងរាំប្រជាប្រិយ

**ក. ពេលសំដែង**

របាំនេះអាចលើកយកមកសំដែងគ្រប់កាលៈទេសៈតាមការនិយមចូលចិត្តរបស់ប្រជាជន គឺអាចសំដែងពេលណាក៏បានអាស្រ័យដោយការកំណត់របស់ប្រជាជន ពិសេសគឺពេលទំនេរពីការងារ ។

**ខ. ទីកន្លែង**

របាំប្រជាប្រិយមិនរើសទីតាំងសំដែង ដោយពុំចាំបាច់សំដៅតែលើពិធីបុណ្យ ពិធីទាក់ទងជំនឿទេ ។ កន្លែងសំដែងបាន គឺអាចនៅលើការដ្ឋានពលកម្មណាមួយ ម្លប់ឈើ ទីលានស្រឡះល្ហម វត្តអារាមដែលគេយល់ថាមានស្ថានភាពអាចអោយគេសំដែងបាន ។

**គ. បំណង**

- របាំប្រជាប្រិយបំរើផលប្រយោជន៍មហាជន ព្រោះវាជារបាំដែលផុសចេញពីមជ្ឈដ្ឋានប្រជាជន ។ វារំលឹកឡើងពីអនុស្សាវរីយ៍អ្វីមួយដែលជាស្នាដៃរបស់ប្រជាជន ។ ជាបទពិសោធលើការងារដែលគេធ្លាប់ជណ្ដើមបាន រួចផ្ទេរបទពិសោធដល់គ្នាទៅវិញទៅមក ។
- សំរាប់ធ្វើការបកស្រាយសកម្មភាពប្រព្រឹត្តទៅនៃជីវភាពប្រជាជនបង្កនូវភាពសប្បាយរីករាយ រំភើបញាប់ញ័រពីក្នុងខ្លួនប្រកបដោយលក្ខណៈថ្លៃថ្នូរបំផុត ។

### ចំណុចខុសគ្នាលើមធ្យោបាយសំដែងនៃរាំប្រពៃណី និង របាំប្រជាប្រិយ

កន្លងមក យើងបានឃើញចំណុចផ្ទុយគ្នាលើពេលវេលា ទីកន្លែង បំណងនៃការសំដែងរបាំប្រពៃណី និង របាំប្រជាប្រិយ ។ ការផ្ទុយគ្នានេះ យើងអាចយកមកវិភាគបានថា គ្រប់របាំប្រពៃណីទាំងអស់ ច្រើនមានការជិតស្និទ្ធស្និតរមួតទៅនឹងជំនឿសាសនា ទំនៀមទំលាប់ដែលប្រជាជនយើងធ្លាប់បានប្រកាន់យក ដើម្បីអប់រំ បន្ទុំចិត្តគំនិតស្មារតីខ្លួនអោយល្អ និង បានសុខសាន្ត ។ ចំណែកឯរបាំប្រជាប្រិយ ជារបាំដែលមានភាពសាមញ្ញ ។ វាត្រូវបានប្រជាជននិទាន ដំណាល រៀបរាប់ ច្រៀងរាំបង្ហាញត។គ្នាពីម្នាក់ទៅម្នាក់ទៀត ។ ដូចនេះ ប្រជាជនណាក៏អាចសំដែងបាន ដោយគ្រាន់តែគេធ្វើការពិនិត្យសង្កេតពីសិល្បករដែលបានសំដែងអោយគេឃើញរួចមក ។

ដើម្បីញែកបន្ថែមពីរបាំប្រពៃណី និង របាំប្រជាប្រិយអោយដាច់ស្រឡះ យើងសូមធ្វើការបង្ហាញពី "មធ្យោបាយការសំដែង" របស់របាំទាំងពីរនេះដូចតទៅ ÷

### មធ្យោបាយសំដែងនៃរាំប្រពៃណី

**ក- ចង្វាក់-តន្ត្រី**

- ច្រើនមានភាពយឺត។ ស្រទន់ លន្លង់លន្លោច (សំរបទៅតាមឧិដ្ឋភាពព្រៃភ្នំក្រំថ្ម ព្រលឹង ។ មានលំនាំជាការលួងលោម អង្វរករ គួញគ្នែរ គោរពកោតខ្លាច) ។
- ឧបករណ៍ភ្លេងប្រគំពីមុនមកមាន "ទ្រ ខ្លុយ សាដៀវ អង្កួច" ។

ខ- ទំនុកច្រៀង

- ជាទូទៅមានលាយឡំពាក្យបុរាណ ពាក្យជនជាតិ ឃ្លោងឃ្លាប្រយោគបែបបុរាណមានចំណាស់យូរយារមកហើយ ។
- ពេលច្រៀងច្រើនធ្វើសំលេងបង្ហួស រជីន១ បន្ទាយវែង១ ។

គ- ក្បាច់របាំ

ការរាំមានចលនាកែច្នៃពីកាយវិការសត្វ ធម្មជាតិ ។

ឃ- សកម្មភាពសំដែង

- មានភាពឃឹត១ រង្វើល១កាយវិការមិនលោតហក់ គឺពុំមានចលនាស្វាហាប់ ។
- ពុំមានចលនាក្រមិចក្រមើម គឺផ្តោតទៅលើមនោសញ្ចេតនាស្ងប់ស្ងៀម ។

ង- ការតុបតែង និង ការស្លៀកពាក់

ការតុបតែង មានភាពហ៊ឹកហ៊ាក់ប្រាកដប្រជាគ្រប់គ្រាន់តំរូវតាមពិធីដែលគេប្រារព្ធឡើង (វត្ថុជាដង្វាយផ្សេង១) ។ សំលៀកបំពាក់មានពណ៌ចំរុះឆើតឆាយ យកតាមរបៀបសម័យបុរាណ "អង្គរ" គឺខោលើក្បាលជង្គង់ អាវសន្ទះប្រើក្រវាត់ចង្កេះ ឬស្លៀកក្បិន ។ សំលៀកបំពាក់មានទ្រង់ទ្រាយទៅតាមប្រភេទរបាំ ឬតាមការនិយមនៃប្រជាជននាសម័យដែលខ្លួនរស់នៅក៏សឹងមាន ។

## មធ្យោបាយសំដែងនៃរបាំប្រជាប្រិយ

ក. ភ្លេង-ចង្វាក់

- ចង្វាក់មានលក្ខណៈញាប់រន្ថើន រហ័សរហួនប្រកបដោយស្នូរយ៉ាងស្វាហាប់បំផុត ។
- ឧបករណ៍តន្ត្រី គឺច្នៃប្រឌិតពីតន្ត្រីប្រពៃណី មហោរីរួមចូល និង តន្ត្រីសម័យថែមទៀតក៏សឹងមាន ។

ខ. ទំនុកច្រៀង

ពាក្យពេចន៍ដែលសាមញ្ញជាសំដីប្រជាជនធ្លាប់ប្រាស្រ័យគ្នាជារៀងរាល់ថ្ងៃ ។ ការច្រៀងមានលក្ខណៈម៉ាត់១ ពុំបង្ហួសតំអូញតំអែពេក ។

អត្ថន័យចំរៀង បញ្ជាក់ពីការអបអរសាទរ ត្រេកអរនឹងការងារ លាយឡំនឹងពាក្យលែបខាយបញ្ជិតបញ្ជៀងទៅវិញទៅមក ។ ប៉ុន្តែពាក្យនោះមានការរិះគន់កែលំអ ល្អកល្អិន ស្របតាមសីលធម៌រស់នៅ និង ចរិតពិតរបស់ជាតិខ្មែរពិត១ ។

<u>**កំណត់សំគាល់:**</u>

- របាំនេះអាចសំដែងដោយមានការច្រៀងជាមួយភ្លេងអមដោយការទះដៃបន្ទរ
- របាំខ្លះពុំប្រើចំរៀងទេ តែត្រូវប្រើស្នូរនៃតន្ត្រីធ្វើជាចង្វាក់រាំ ។ ឧទាហរណ៍ : (របាំមានច្រៀង)
- របាំត្រឡោក របាំគោះអង្រែ របាំតែន របាំក្ងៀង របាំមេអំបៅ របាំជនជាតិ ។ល។ ឧទាហរណ៍ : របាំឥតចំរៀង
- របាំនេសាទ របាំក្រាប របាំក្ងោកពោធិសាត់ របាំកន្សែងស្នេហ៍ (ចាម) ។

**គ. ក្បាច់រាំ**

ក្បាច់រាំប្រកបដោយសិល្បវិធីប្លែកៗ ដែលលើកឡើងនូវសកម្មភាពការងារណាមួយជាផ្ទាំងទស្សនីយភាព។ របាំនេះបង្កប់ទៅដោយសិល្បៈសោភ័ណពុំដូចរបាំប្រពៃណីនោះទេ ។

**ឃ. សកម្មភាពសំដែង**

កាយវិការសិល្បករ មានភាពស្វាហាប់ ហ៊ឹកហ៊ាក់ ហោកញ្ញៀវ ញញឹមញញែម ក្រមិចក្រមើម ញាក់មុខមាត់បង្កើតបរិយាកាសអឹងកងរីករាយពន់ប្រមាណ ។

**ង. ការតុបតែង និង ការស្លៀកពាក់**

- ការតុបតែងទីកន្លែងសំដែង ស្របទៅតាមប្រភេទរបាំ ជាវាលលំហ ដោយយកធម្មជាតិ ជាឆាកតែម្តងក៏មាន
- សំលៀកបំពាក់ចំរុះពណ៌ គឺអាចពណ៌លាតចំរុះលាយឡំ និង បុរាណសម័យ ប៉ុន្តែរក្សានូវលក្ខណៈជាតិខ្មែរច្បាស់លាស់ ។

## ៣. ភាពកំលាយនៃរបាំនីមួយៗ

**ក- របាំប្រជាប្រិយក្លាយជារបាំប្រពៃណី**

ពេលនេះ យើងលើកយករបាំប្រជាប្រិយមួយមកពិនិត្យ គឺរបាំកន្សែងស្នេហ៍ (ជនជាតិចាម) ។

របាំនេះជនជាតិចាមបានចាត់ទុកថា ជា "របាំប្រជាប្រិយ" ក្នុងគ្រាដំបូង ។ ប៉ុន្តែដោយរបាំនេះមានលក្ខណៈទាក់ទងទៅនឹងទំនៀមទំលាប់មួយរបស់ចាម គឺការប្រើមន្តអាគមស្នេហ៍ស្នេកនោះជាដើមហេតុធ្វើអោយគេកំណត់ថាវាជា "របាំប្រពៃណី" ទៅវិញ ។

**មូលហេតុនៃការកំលាយរបស់របាំកន្សែងស្នេហ៍**

តាមដែលខ្ញុំបានស្តាប់ប្រសាសន៍លោកព្រឹទ្ធបុរស **ឆេង ផុន** លោកមានប្រសាសន៍ថា "របាំនេះ ខ្មែរយើងបានយកមកសំដែងពីឆ្នាំ ១៩៦៥" ។ លោកបានបញ្ជាក់ថា ៖ ការកកើតនៃរបាំនេះ អាស្រ័យមកពីសិល្បករខ្មែរយើងបានឃើញជនជាតិចាមយកទៅសំដែងជាទូទៅនៅប្រទេសឥណ្ឌូនេស៊ី (ជនជាតិចាមរស់នៅប្រទេសឥណ្ឌូនេស៊ី) ។ ក្រោយពីវិលត្រឡប់មកមាតុភូមិវិញ សិល្បករខ្មែរបានយករបាំនេះមកច្នៃប្រឌិតដោយបញ្ចូលសាច់ភ្លេង ក្បាច់រាំតាមលក្ខណៈខ្មែរ ។ លុះដល់សិល្បករខ្មែរចេញសំដែងក្នុងប្រទេសក៏ដូចជាយកទៅសំដែងនៅប្រទេសឥណ្ឌូនេស៊ីវិញ បានទទួលការកោតសរសើរគាំទ្រយ៉ាងក្លៀវក្លាពីជនជាតិមូស្លីនដែលរស់នៅស្រុកខ្មែរ និង ឥណ្ឌូនេស៊ី ។ គ្រានេះហើយ គេបានសំរេចចិត្តថា "របាំកន្សែងស្នេហ៍" ជារបាំប្រពៃណី ។ តែតាមពិតជារបាំប្រជាប្រិយទេ ។

**ខ- របាំប្រពៃណីក្លាយជារបាំប្រជាប្រិយ**

ជាទូទៅ របាំប្រជាប្រិយក្លាយមកជារបាំប្រពៃណី គឺកំរមានណាស់ ។ ប៉ុន្តែបើរបាំប្រពៃណីក្លាយមកជារបាំប្រជាប្រិយ គឺមានចំនួនច្រើនបំផុត ។ បានសេចក្តីថា សារធាតុនៃរបាំប្រពៃណីនេះ បានរលាយខ្លួនចូលជ្រាបក្នុងមជ្ឈដ្ឋានរស់នៅរបស់ប្រជាជន ។ ប្រជាជននិយមចូលចិត្ត ចេះចាំសំដែងគ្រប់ៗគ្នា ។ម្យ៉ាងទៀត ប្រភពនៃរបាំ

ប្រពៃណីទាក់ទងទៅនឹងតម្រាព្រេងនិទានខ្មែរ ហើយខ្មែរនិយមអានឥតដាច់ ។ ទីបំផុតគេក៏យល់ថា : វាជារបាំប្រជាប្រិយគ្រប់ៗគ្នាទៅ ។

## មូលហេតុនៃកំលាយពីរបាំប្រពៃណីមករបាំប្រជាប្រិយ

មូលហេតុនៃកំលាយនេះមកពីកត្តាសំខាន់ បី គឺ ÷

**១- កត្តាតំរូវការរបស់ប្រជាជន**

កន្លងមកក៏ដូចជាបច្ចុប្បន្ន ប្រជាជនបានចាត់ទុកខ្លួនជាអ្នកចាត់ចែងធានាខុសត្រូវលើជោគវាសនាខ្លួនដោយខ្លួនឯង ។ ដូចនេះ ÷

- សិល្បៈត្រូវការបែរមកបំរើផ្ទាល់នឹងជីវភាព បំរើសេចក្តីស្រេកឃ្លាន ផ្នែកស្មារតី សតិអារម្មណ៍របស់ខ្លួនដែលជាម្ចាស់សង្គមជាតិទាំងមូល ។
- ប្រជាជនចាត់ចែងរៀបចំការសំដែងគ្រប់ពេលវេលា តាមការចូលចិត្តរបស់ខ្លួន ដោយពុំរង់ចាំពេលវេលាទីកន្លែងស្របនឹងរបាំប្រពៃណីទេ ។
- ប្រជាជនជាជំនួយដោះស្រាយនូវបញ្ហាស្មុគស្មាញ ។ គេយល់ទៀតថា អាទិទេព អ្នកតា ជាស្រមោលអរូបីតាមរយៈការយល់ដឹងពីវិទ្យាសាស្ត្ររូប និងការពិសោធផ្ទាល់ក្នុងការងាររាប់លានឆ្នាំ ។

ប្រការនេះហើយ នាំអោយប្រជាជនអូសទាញរបាំប្រពៃណីជាបណ្តើរៗអោយចូលក្នុងលំដាប់នៃរបាំប្រជាប្រិយស្ទើរតែទាំងអស់ ។

**២- កត្តាមធ្យោបាយនៃការសំដែង**

ជាធម្មតា របាំប្រពៃណីក៏ត្រូវរាប់បញ្ចូលជាសិល្បៈផងដែរ ។ ការសំដែងតែងបង្កប់នូវ :

- ចង្វាក់រាំរពើន ច្រៀងបន្ទរបង្កនូវភាពរំភើប រីករាយឥតដាច់ ។ ទោះជារបាំប្រពៃណីមានចលនារាំមិនស៊ីគ្នានឹងរបាំប្រជាប្រិយដូចដែលយើងបានរៀបរាប់មកហើយក្តី ក៏បច្ចេកទេសរាំមានលក្ខណៈគួរអោយពេចពិលរមិលមើលដែលពុំអាចរារាំងចិត្តប្រជាជនអោយធ្វើតាម និង ក៏បាននាំគ្នាហ្វឹកហាត់សំដែងចេញភ្លាមៗគ្នាឡើង ។ ករណីនេះហើយ ធ្វើអោយរបាំប្រពៃណីបង្ហោនខ្លួនជារបាំប្រជាប្រិយ ។

**៣- កត្តាសំដែងទាក់ទងទៅនឹងកីឡា និង ជីវភាពប្រចាំថ្ងៃ**

យើងឃើញថាបច្ចេកទេសសំដែងនៃរបាំប្រពៃណី មានលក្ខណៈដូចជាក្បាច់ប្រដាល់ ហក់លោត ត្រវីខ្លួនលូនក្រាប ។ ចំពោះភ្លេងវិញ មានរបៀបជាភ្លេងសំពះគ្រូ ភ្លេងប្រដាល់ ឬក៏ភ្លេងគ្រាប់តាមដំណើរលោតកញ្ឆេងរបស់សត្វ ។

ទិដ្ឋភាពនេះ បានជិតដាមជាប់ក្នុងអារម្មណ៍ប្រជាជន ជំរុញអោយចូលចិត្ត មមៃនឹកគិតតែពីលក្ខណៈសំដែងនៃរបាំនេះ ។ ពេលនោះហើយ គេអបអរសាទរគាំទ្រវារហូតដល់ចាត់ទុកវាជារបាំប្រជាប្រិយឡើង ។

លោក : ខេត ធឿន

ប្រធានការិ.អប់រំ និង គ្រប់គ្រងនៃវិទ្យាស្ថានជាតិអប់រំ

# ការគោរពច្បាប់ធម្មជាតិ និង ការត្រួតត្រាលើធម្មជាតិ

មនុស្សកើតមករស់នៅជាមួយធម្មជាតិ ព្រោះសរីរៈរបស់មនុស្សជាភាវៈ គឺជាវត្ថុធាតុនៃធម្មជាតិ ជាហេតុអោយមនុស្សសំរបទឹងតំរូវការជីវភាពរបស់ខ្លួនតាមធម្មជាតិ ប៉ុន្តែចាប់តាំងពីមនុស្សរកឃើញភ្លើងពេលណាមក មនុស្សមានគំនិតចង់ត្រួតត្រាលើធម្មជាតិ ។ តើករណីណាប្រសើរជាង ? តើករណីណាប្រកបដោយសីលធម៌ជាង ?

## ១_ មនុស្សគោរពធម្មជាតិ

ច្បាប់ធម្មជាតិមានន័យដូចម្ដេច ?

ច្បាប់ធម្មជាតិសំគាល់ដំណើរប្រព្រឹត្តទៅនៃធម្មជាតិ គឺចលនាវិលវល់ក្នុងវដ្តសង្សារនៃភាវៈ ÷

- ព្រះអាទិត្យរះឡើងហើយលិចទៅវិញ ដើម្បីរះឡើងជាថ្មីម្ដងទៀត
- រុក្ខជាតិ មនុស្ស សត្វ កើតឡើងហើយស្លាប់ទៅវិញ
- អ្វីៗទាំងអស់ក្នុងភាវៈត្រូវតែផ្លាស់ប្ដូរ
- អ្វីៗទាំងអស់ក្នុងភាវៈរមែងមានគូ តាំងពីប្រុសស្រី ញីឈ្មោល ល្អអាក្រក់ សុខទុក្ខ ឧស្សាហ៍ ខ្ជិល ខ្ពស់ទាប...

ទាំងអស់នេះជាទ្រឹស្ដីធម្មជាតិដែលព្រះពុទ្ធអង្គតែងសំដែងក្នុងត្រៃលក្ខណ៍ : ទុក្ខំ អនិច្ចំ អនត្តា ។

មនុស្សគោរពច្បាប់ធម្មជាតិ គឺមនុស្សត្រូវសំរបសំរួលជីវភាពរបស់ខ្លួនតាមតំរាយផ្លូវធម្មជាតិ ។

គោរពច្បាប់ធម្មជាតិរបស់បុគ្គល គឺសេរីភាព ព្រោះបុគ្គលកើតមកមានសេរីភាពពិតប្រាកដ ប៉ុន្តែសង្គមធ្វើអោយបាត់បង់សេរីភាព ។ ត្រង់ចំនុចនេះ លោក សង់សាក់ រូស្សូ (J.J Rousseau) អ្នកប្រាជ្ញបារាំងម្នាក់នៅសតវត្សទី ១៨ បានថ្កោលទោសលើសង្គមដោយយល់ថា "ក្មេងកើតឡើងល្អសោះ ប៉ុន្តែសង្គមធ្វើអោយក្មេងពុករលួយ" ។ ប៉ុន្តែលោក វ៉ុលទែរ[១] រស់នៅជំនាន់លោក រូស្សូ ពុំទំលាក់កំហុសទៅលើសង្គមទេ គឺអោយតំលៃលើការអប់រំវិញ ។

នេះជាច្បាប់ធម្មជាតិតាមអន្តរបុគ្គល ÷

- អ្នកឆ្លាតបានចំនេញលើអ្នកពុំឆ្លាត
- អ្នកប្រសប់រស់នៅបានស្រួលជាងអ្នកមិនប្រសប់
- អ្នកមានប្រាជ្ញា គ្រាន់បើជាងអ្នកល្ងង់ ទោះបីប្រាសចាកសីលធម៌ក៏ដោយ

ចំនែកឯច្បាប់ធម្មជាតិក្នុងសង្គមរួមមានទ្រឹស្ដី "ត្រីធំស៊ីត្រីតូច" ។

ដូចនេះ ក្នុងធម្មជាតិគ្មានមនុស្សធ្វើល្អទេ គ្មានមនុស្សពុំដែលគិតប្រយោជន៍ផ្ទាល់ខ្លួន គឺមនុស្សសុទ្ធតែចាំធ្វើអាជីវកម្មលើមនុស្សផងគ្នាអោយតែមានឱកាស ។

(១) ឈ្មោះដើម François Marie Arouet

## ២. មនុស្សត្រួតត្រាលើធម្មជាតិ

ចាប់តាំងពីមនុស្សរកឃើញភ្លើង មនុស្សមានបំនងត្រួតត្រាលើធម្មជាតិ ព្រោះភ្លើងអាចធ្វើអោយភាវៈប្រែប្រួលតាមបំនងរបស់មនុស្សដូចជា សាច់ឆៅទៅជាឆ្អិន វត្ថុរាវទៅជារឹង កខ្វក់ទៅជាស្អាត... ។

ក្នុងគោលបំនងត្រួតត្រាលើធម្មជាតិនេះ មនុស្សមានគំនិតដូចតទៅ ÷

- មិនចង់អោយមនុស្សមានសេរីភាពហួសព្រំដែន ទើបបង្កើតច្បាប់ឡើង
- មិនចង់អោយអ្វីៗដែលមានគំលាតគ្នារវាងអន្តរបុគ្គលមានតទៅទៀត ដោយអប់រំមនុស្សអោយមានចំនេះដឹងគ្រប់គ្រាន់ ពុំចង់អោយមនុស្សមានប្រៀបលើមនុស្សផងគ្នា អោយចេះជួយយកអាសាគ្នាពោលគឺ
    - មិនចង់អោយបុគ្គលខ្លះសប្បាយតែម្នាក់ឯង
    - មិនចង់អោយបុគ្គលកសាងសេចក្តីសុខលើគំនរទុក្ខអ្នកដទៃ
    - មិនចង់អោយអ្នកខ្លាំងជិះជាន់អ្នកខ្សោយ
    - មិនចង់អោយអ្នកមានប្រាជ្ញាធ្វើអាជីវកម្មលើអ្នកល្ងង់
    - មិនចង់អោយមនុស្សស្លាប់តាមបែបធម្មជាតិ
    - មិនចង់អោយមនុស្សទាំងអស់នៅក្រោមឥទ្ធិពលនៃធម្មជាតិ ។

ពិតមែនតែមនុស្សចង់ត្រួតត្រាលើធម្មជាតិ តែមនុស្សពុំបានសំរេចបំនងរបស់ខ្លួនមួយរយភាគរយទេ អាចថាមិនដល់ ៥០% ផង ដរាបណាមនុស្សពុំទាន់រើបំរះខ្លួនចេញរួចពីសេចក្តីស្លាប់ ។

ដូចនេះ ÷

- មនុស្សត្រូវគោរពច្បាប់ធម្មជាតិ តែប្រកបដោយសីលធម៌ គឺត្រូវចៀសវាងករណីដែលមនុស្សអាចធ្វើអាជីវកម្មលើមនុស្សផងគ្នា ។
- មនុស្សត្រូវរៀបចំខ្លួនត្រួតត្រាលើធម្មជាតិ ទោះបីពុំបានតាមបំនងក្តី ក៏ត្រូវតែខំត្រួតត្រាលើធម្មជាតិតទៅទៀត ព្រោះទោះបីមនុស្សនៅតែស្លាប់ក៏ដោយ ក៏ត្រូវខំចៀសការស្លាប់តាមបែបធម្មជាតិយ៉ាងហោចណាស់ក៏ស្វែងរកថ្នាំសង្កូវបន្តអាយុបានយឺនយូរតទៅមុខទៀតដែរ ។

ជារួម យើងឃើញថាពុំមានករណីមួយណាប្រសើរជាងករណីមួយណាទេ ព្រោះមនុស្សរស់នៅក្នុងការអនុវត្តទ្រឹស្តីទាំងពីរបែបតាមពេលវេលា ។ ប៉ុន្តែ គួរអោយតំលៃទៅលើមតិដែលនិយមទ្រឹស្តីមនុស្សត្រួតត្រាលើធម្មជាតិ ដើម្បីអោយមនុស្សក្លាយទៅជាម្ចាស់នៃធម្មជាតិក្នុងបំនងស្វែងរកសុខុមាលភាពសំរាប់មនុស្សជាតិ និងរំដោះមនុស្សអោយផុតចេញពីនឹមនៃច្បាប់ធម្មជាតិ ។

លោកស្រី កែវ សុប្ញរិទ្ធ

សាស្ត្រាចារ្យចិត្តវិទ្យា-អប់រំ នៃវិទ្យាស្ថានជាតិអប់រំ

✱✱✱✱✱✱



# ចិត្តវិទ្យា-អប់រំ

## ចិត្តរំភើប និង កំលាំងចិត្ត

### ១~ សេចក្តីផ្តើម

តើអ្វីទៅជាកំលាំងចិត្ត និង ចិត្តរំភើប ? ហេតុអ្វីបានជាមនុស្សធ្វើអ្វីដែលគេចង់ធ្វើ ? តើអ្វី និង មូលហេតុអ្វីដែលជំរុញចិត្តមនុស្សអោយធ្វើសកម្មភាព និង សំដែងអាកប្បកិរិយាឡើង ? ហេតុអ្វីបានជាសិស្សមួយចំនួនមិនបានខិតខំរៀនសូត្រ ដើម្បីទទួលបាននិទ្ទេសល្អក្នុងពេលប្រលង ?

> **ចិត្តរំភើប**

ចិត្តរំភើបជាអារម្មណ៍ខ្លាំងក្លា ។ ចិត្តរំភើបមានសមាសធាតុរបស់វាចំនួន ប្រាំបី ដែលបែងចែកជា ៤ ក្រុមផ្ទុយគ្នា ។ សមាសធាតុផ្ទុយគ្នាទាំង ៤ ក្រុមនោះរួមមាន : សេចក្តីរីករាយ ផ្ទុយជាមួយភាពទុក្ខព្រួយ, ការពេញចិត្តទទួលយក ផ្ទុយជាមួយការស្អប់ខ្ពើម, ការគិតស្មានទាយទុកជាមុន ផ្ទុយនឹងការភ្ញាក់ផ្អើល, កំហឹង ផ្ទុយនឹងការភ័យខ្លាច។ កាលណាមនុស្សមានការត្រៀមរៀបចំជាមុន ពួកគេមិនមានការភ្ញាក់ផ្អើល ហើយពេលណាមនុស្សមានការរីករាយ គេនឹងមិនមានអារម្មណ៍ទុក្ខព្រួយឡើយ ហើយម្យ៉ាងវិញទៀតបើគេមានការពេញចិត្ត ការចូលចិត្តទទួលយកអ្វីមួយហើយ គេមិនមានអារម្មណ៍ស្អប់ខ្ពើមរអើមឡើយ ។ ចិត្តរំភើបនាំអោយមនុស្សកើតមានកំលាំងចិត្ត និង បញ្ចេញសកម្មភាពជាវិជ្ជមាន រឺអវិជ្ជមាន ។ កំលាំងចិត្តនេះ ត្រូវបានចិត្តវិទូធ្វើការយកចិត្តទុកដាក់ និង ធ្វើការបកស្រាយផ្សេងពីគ្នា ។

> **កំលាំងចិត្ត**

កំលាំងចិត្តជាបញ្ញត្តិទូទៅដែលមាននៅក្នុងការសិក្សាចិត្តវិទ្យា ឬជាបញ្ញត្តិចិត្តវិទ្យា ។ កំលាំងចិត្តជាលំនាំផ្លូវចិត្ត និង កាយសំរាប់ចាប់ផ្តើមអោយមានការសំដែងអាកប្បកិរិយាបន្ត និង បញ្ចប់អាកប្បកិរិយានោះ ។ ការសិក្សាកំលាំងចិត្ត ជាការសិក្សាពីបុព្វហេតុនៃអាកប្បកិរិយា ។ ចិត្តវិទូយកចិត្តទុកដាក់លើបុព្វហេតុនៃអាកប្បកិរិយាដែលកកើតចេញពីមជ្ឈដ្ឋាន និង ចេញពីបុគ្គល ។

*ឧទាហរណ៍* : ក្រុមមនុស្សប្រមូលផ្តុំគ្នាធ្វើបាតុកម្ម គឺជាលទ្ធផលនៃកំលាំងចិត្តរបស់គេដែលបណ្តាលមកពីកត្តានយោបាយ ដែលជាកត្តាមជ្ឈដ្ឋាននាំអោយគេសំដែងអាកប្បកិរិយាបែបនេះ។ ម្យ៉ាងវិញទៀត ការសំដែងអាកប្បកិរិយាចំលែកខុសពីប្រក្រតីរបស់មនុស្ស អាចបណ្តាលមកពីបុព្វហេតុនៃកត្តាសរីរាង្គកាយ ដោយខួរក្បាលរបស់បុគ្គលនោះ

មានការខូចទ្រង់ទ្រាយ ឬមិនធម្មតា ។ ដំណើរការមិនធម្មតានៃខួរក្បាលនេះ ជាហេតុនាំអោយគេប្រព្រឹត្តអាកប្បកិរិយាពាលាខុសពីសកម្មភាពមនុស្សធម្មតា ។

កំលាំងចិត្តឆ្លើយតប និង ឆ្លុះបញ្ចាំងទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃ ។ មនុស្សដែលមានកំលាំងចិត្តខ្លាំង ច្រើនតែធ្វើការងារ ឬប្រព្រឹត្តអ្វីមួយបានកាន់តែប្រសើរ ខណៈពេលមនុស្សមានកំលាំងចិត្តមិនគ្រប់គ្រាន់ ធ្វើនូវកិច្ចការអ្វីមួយមិនសូវទទួលបានជោគជ័យ ។ មនុស្សដែលមានជំនក់ចិត្តខាងផ្នែកអ្វីមួយ តែងតែមានកំលាំងចិត្តដែលនាំអោយសំរេចបំណងរបស់គេបានកាន់តែប្រសើរឡើង ។ ផ្អែកតាមកំលាំងចិត្តនេះ គេសង្កេតឃើញថា ក្រុមកីឡាម្ចាស់ផ្ទះច្រើនតែទទួលបានជោគជ័យជាងក្រុមកីឡាមកពីទឹកដីផ្សេង ទោះជាក្រុមទាំងពីរនេះមានកិរិតសមត្ថភាពលេងប្រហាក់ប្រហែលគ្នាក៏ដោយ នេះទំនងជាមកពីបុព្វហេតុការផ្តល់កំលាំងចិត្តពីក្រុមអ្នកគាំទ្ររបស់ពួកគេ ដែលជំរុញអោយចិត្តរបស់គេលេងបានកាន់តែល្អឡើង ។ កំលាំងចិត្តនេះ មិនត្រឹមតែមាននៅលើមនុស្សប៉ុណ្ណោះទេ ថែមទាំងមាននៅតាមបណ្តាប្រភេទសត្វផ្សេងទៀត ដូចជាសត្វចតុបាត បក្សី និង ប្រភេទសត្វផ្សេង ទៀត ។

## ២. ទស្សនៈរបស់ចិត្តវិទូចំពោះកំលាំងចិត្ត

### ក- ចិត្តវិទូ Sigmund Freud (1856-1939)

លោក សិហ្គម៉ង់ ហ្វ្រីដ ជាចិត្តវិទូជាតិអូទ្រីសផ្នែកចិត្តសាស្ត្រវិភាគ ។ គាត់ជាបិតាចិត្តវិទូ ។ គាត់បានផ្តល់អំណះអំណាងទៅលើកំលាំងចិត្តនេះថា កំលាំងចិត្តមានប្រភពចេញពីកំលាំងអញ្ញាណ ។ មនុស្សធ្វើសកម្មភាពដោយកំលាំងអញ្ញាណដែលយើងមិនបានដឹងពីមូលហេតុដែលនាំអោយយើងសំដែងអាកប្បកិរិយាបែបនេះទេ ។ យោងតាមទ្រឹស្តីចិត្តសាស្ត្របានអោយដឹងថា រាល់សកម្មភាព និង អាកប្បកិរិយា គឺជាលទ្ធផលនៃកំលាំងសភាវគតិផ្នែកជីវសាស្ត្រដែលមានមូលហេតុសំខាន់ចំនួន ពីរ គឺ កំលាំងចិត្តតំរូវការស្នេហាផ្លូវភេទ និង កំលាំងចិត្តហឹង្សាឃោរឃៅកំរោលចូល ។ តំរូវផ្នែកផ្លូវភេទ ជាតំរូវការសំរាប់ជីវិតរស់នៅដោយខានមិនបាន និង តំរូវការផ្នែកកំលាំងកំរោល ដើម្បីគេចចេញពីសេចក្តីស្លាប់ ។ កត្តាផ្លូវភេទ កើតមានឡើងនៅខណៈពេលម្តាយថ្នាក់ថ្នម យកចិត្តទុកដាក់ថែទាំកូនដោយទឹកមុខ កាយវិការទន់ភ្លន់ កក់ក្តៅទៅលើទារក រីឯកំលាំងចិត្តហឹង្សា គេឃើញមាននៅពេលក្មេងវាយប្រតប់គ្នា ត្រូវតែធ្វើបាបកាលនៅកុមារវ័យ ។

*ឧទាហរណ៍* : សត្វខ្លាខិតខំប្រមាញ់ប្រភេទសត្វទន់ខ្សោយ ដូចជាសេះបង្កង់ គោព្រៃ សំរាប់ជាអាហាររបស់ខ្លួននៅខណៈពេលសត្វខ្សោយនោះខិតខំរត់គេចខ្លួនចេញពីសេចក្តីអន្តរាយជីវិត នេះជាកំលាំងចិត្តដែលបណ្តាលអោយធ្វើអំពើរត់ចេញ រឺដកខ្លួនអោយឆ្ងាយចេញពីអញ្ញាណ ។ ផ្អែកលើឧទាហរណ៍នេះ គេអាចចាត់ថា កំលាំងចិត្តជាឧបករណ៍ពីរប្រភេទ ដើម្បីរស់ផង( ការដេញចាប់សត្វសំរាប់ការរស់នៅរបស់សត្វខ្លា) និងដើម្បីគេចចេញពីការភ័យផង( ព្រោះភ័យ) របស់សេះបង្កង់ ។ លោក Freud យល់ថា កំលាំងចិត្តជំរុញអោយចាប់ផ្តើមធ្វើអំពើអ្វីមួយ រឺមិនចង់ធ្វើអំពើអ្វីមួយ ( មនុស្សអសកម្ម) បណ្តាលមកពីមូលហេតុភាពកក់ក្តៅដែលកុមារមិនបានទទួលពីម្តាយ រឺអំពើឃោរឃៅដែលទទួលពីកុមារភាព ។ ទស្សនៈរបស់លោក Freud មានលក្ខណៈអវិជ្ជមានដែលខុសពីទស្សនៈរបស់លោក អាប្រាហាម ម៉ាស្លូ ។

Sigmund Freud បានពន្យល់ថា ភាពកក់ក្តៅ ការញញឹម លួងលោម បបោសអង្អែលរបស់មាតាចំពោះទារក និង កុមារតូច ជាការឆ្លើយតបទៅនឹងតំរូវការភេទ (sexuality)របស់កុមារ ដែលត្រូវតែបានបំពេញដោយខាន

មិនបានដូចតម្រូវការចំណីអាហារផែរ ។ បើមានតែអាហារខ្វះតម្រូវការភេទនេះ កុមារមិនអាចរស់រានមានជីវិតជាមនុស្សធម្មតាបានឡើយ ។ ពិភពលោកយកបានទស្សនៈរបស់ Freud ទៅអនុវត្តដើម្បីបង្កើតអង្គការសង្គ្រោះកុមារអប់រំមាតា



សេចក្ដីស្នេហារវាងម្ដាយនិងកូន

ដែលមានផ្ទៃពោះ អោយយល់ដឹងអំពីបញ្ហាគាំពារទារក គាំពារកុមារតូចដែលកំព្រា និង កុមារក្រីក្រងាយក្នុងការរងគ្រោះ ។ អង្គការទាំងនោះ មានអង្គការគ្រួសារយើង អង្គការ UNICEF អង្គការ Red Banna សុទ្ធតែនៅក្នុងផែនការគោលនៃការអប់រំសំរាប់ទាំងអស់គ្នាក៏មានចែងអំពី "ពង្រីក និង កែលំអការអប់រំ និង គាំពារកុមារតូច... អភិវឌ្ឍការលូតលាស់ និង ការរស់រានមានជីវិតរបស់កុមារកម្ពុជា... តាំងពីកំណើតរហូតដល់ពេលចូលសិក្សា" ផែនការជាតិសំរាប់អប់រំទាំងអស់គ្នា ។

Sigmund Freud បានបកស្រាយពីកំលាំងចិត្តដែលកប់យ៉ាងជ្រៅនៅក្នុងអញ្ញាណដែលជាផលវិបាកកាលនៅជាកុមារភាព ពេលដែលកុមារមានទំនាក់ទំនងជាមួយកុមារដទៃ ។ កាលណាកុមារត្រូវបានកុមារដទៃវាយដំធ្វើបាប រឺសំឡុតគំរាមកំហែង ។ លុះធំឡើង គេក្លាយជាមនុស្សមានវិបត្តិផ្លូវចិត្តចង់តែធ្វើអំពើឃោរឃៅ រឺក៏មិនធ្វើអ្វីទាល់តែសោះ ព្រោះកំលាំងចិត្តដែលកប់នៅក្នុងអញ្ញាណទប់មិនអោយធ្វើអំពើទៅបាន ។



អំពើឃោរឃៅ



អនុស្សាវរីយ៍ដែលកប់ទៅក្នុងអញ្ញាណ

តាមទស្សនៈរបស់ Freud កំលាំងចិត្តដែលកប់យ៉ាងជ្រៅនៅក្នុងអញ្ញាណបណ្ដាលអោយមនុស្សក្លាយទៅជាវិបត្តិផ្លូវចិត្ត ប្រព្រឹត្តអំពើឃោរឃៅដោយខ្វះវិចារណញ្ញាណ រឺក៏នៅស្ងៀមមិនចង់ធ្វើអ្វីទាំងអស់ មូលហេតុបណ្ដាលមកពីចិត្តរើសរឺចិត្តរន្ធត់ដែលកុមារបាត់បង់ផ្នែកថ្នាក់ថ្នមពីមាតាកាលពីកុមារភាព រឺក៏អំពើឃោរឃៅពីកុមារដទៃ ។

ដូចនេះនាយកសាលា និង គ្រូបង្រៀន ត្រូវទទួលខុសត្រូវការពារកុំអោយអំពើឃោរឃៅទៅលើកុមារកើតមាននៅតាមសាលារៀនរបស់ខ្លួន ។ តាមមតិរបស់ Freud ផលវិបាកនឹងកើតមាននៅពេលកុមារនោះក្លាយជាមនុស្សពេញវ័យ ។

(នៅមានត)

បណ្ឌិត អ៊ឹម កុច

❖❖❖❖❖❖

# ដំណើរអភិវឌ្ឍន៍វិស័យអប់រំនៅសហរដ្ឋអាមេរិក (ត)

## V. ចរន្តនៃចលនាកែទម្រង់វិស័យអប់រំ

ចលនាកែទម្រង់វិស័យអប់រំមិនមែនជាចលនាទោលទេ ។ ប្រជាពលរដ្ឋមកពីសហគមន៍ជាច្រើនក្នុងសហរដ្ឋអាមេរិកស្នើសុំអោយមានដំណោះស្រាយដំទូលំទូលាយចំពោះវិស័យអប់រំ ។ ចលនាកែទម្រង់វិស័យអប់រំមានលក្ខណៈខុសពីសម័យមុនៗ ។ រដ្ឋាភិបាលអាមេរិកចេញសេចក្តីសំរេចលើកកំពស់តួនាទីរបស់សាលារៀន ÷

- ជួរគ្រូបង្រៀនជាបញ្ញវន្តដែលមានចំណេះដឹងស្របតាមផ្លូវច្បាប់គរុកោសល្យក្នុងវិជ្ជាជីវៈ
- គ្រូបង្រៀនត្រូវចេះផ្សារភ្ជាប់ចំណេះដឹងវិទ្យាសាស្ត្រទៅនឹងសម្បទាគរុកោសល្យ ក្នុងវិធីសាស្ត្របង្រៀន និង អប់រំសិស្ស

### ជួរគ្រូបង្រៀនជាអ្នកមានវិជ្ជាជីវៈ

អ្នកមានវិជ្ជាជីវៈ ត្រូវបានបែងចែកដាច់ស្រឡះពីពពួកកម្មករ ។ អ្នកមានវិជ្ជាជីវៈអាចធ្វើសេចក្តីសំរេចចិត្តដោយចេះវិនិច្ឆ័យច្បាស់លាស់ទៅលើការងារ និង សេវាកម្មដែលខ្លួនត្រូវអនុវត្ត ។ ទង្វើរបស់អ្នកមានវិជ្ជាជីវៈរួមជាមួយសហសេវិកឋិតនៅក្រោមការដឹកនាំរបស់អង្គការរដ្ឋ និង អង្គការអន្តរជាតិ ។ អ្នកមានវិជ្ជាជីវៈត្រូវការអោយមានកិច្ចគាំទ្រ និង ពេលវេលាសំរាប់ស្តង់ដាអភិវឌ្ឍចំពោះមនុស្សពេញវ័យ (យុវសិស្ស) ÷

- ឆ្លុះបញ្ចាំងមើល និង ពិនិត្យពិច័យមើលទៅលើបញ្ហាដែលពាក់ព័ន្ធនឹងមុខជំនាញ
- រៀបចំអោយមានកិច្ចសហការគ្នា និង ទំនាក់ទំនងជាមួយអ្នកមានវិជ្ជាជីវៈឯទៀត
- ដោះស្រាយបញ្ហាក្នុងការងារ និង បន្លាស់ប្តូរគ្នាក្នុងការបែងចែកម៉ោងបង្រៀន
- មានទំនួលខុសត្រូវទៅតាមមុខវិជ្ជាឯកទេសរបស់ខ្លួន ។

គ្រូបង្រៀនដ៏មានជំនាញ និង គ្រូបង្រៀនថ្មី ត្រូវសាមគ្គីគ្នាក្នុងការអនុវត្តធ្វើអោយកម្មវិធីសិក្សា វិធីសាស្ត្របង្រៀន អប់រំ និង ការគ្រប់គ្រងសមូហភាពសិស្សអោយបានសំរេចក្នុងន័យធ្វើអោយវិជ្ជាជីវៈរបស់ខ្លួនអភិវឌ្ឍ ។

### ភាពក្លាយខ្លួនទៅជាអ្នកមានវិជ្ជាជីវៈ

បទពិសោធក្នុងការស្លៀកពាក់កាលនៅជានិស្សិតត្រូវបានផ្លាស់ប្តូរ ។ អ្នកតែងតែនឹកឃើញដល់ពាក្យសំដីរបស់គ្រូអ្នក កាលអ្នកនៅជាសិស្ស ។ ពេលអ្នកក្លាយខ្លួនជាគ្រូថ្មី អ្នកនឹងចេះវិភាគទៅលើឥទ្ធិពលរបស់អ្នកចំពោះសិស្ស ចំពោះសហសេវិក និង ចំពោះអ្នកឯទៀតក្នុងសង្គម ។ អ្នកកម្ររកឃើញវិធីថ្មីក្នុងការបង្រៀន និង ចេះវិភាគទៅលើលទ្ធផលដែលទទួលបាន ។ ពេលខ្លះធ្វើអោយអ្នកនឹកឃើញដល់វិធីបង្រៀនផ្សេងៗគ្នារបស់គ្រូអ្នក ។ អ្នកខិតខំស្វែងយល់ស៊ីជំរៅ និង ត្រិះរិះពិចារណាទៅលើអាកប្បកិរិយាផ្ទាល់ខ្លួនក្នុងឋានៈអ្នកជាគ្រូបង្រៀន ។

*__ការងារបង្រៀន__* : ជាសិល្បៈ ឬជាវិទ្យាសាស្ត្រ ? ការបង្រៀន ត្រូវបានគេអោយនិយមន័យថា ជាសិល្បៈផង ជាវិទ្យាសាស្ត្រផង ។ អ្នកស្រាវជ្រាវ និង អ្នកអប់រំ ខំព្យាយាមពន្យល់ថា តើការបង្រៀនជាអ្វី ? ។ កិច្ចខិតខំ

ប្រឹងប្រែងបែបនេះ មានសេចក្តីណែនាំថា គេស្រាវជ្រាវរកអោយឃើញនិយមន័យនៃការបង្រៀនល្អ ។

អ្នកអប់រំខ្លះពិពណ៌នាការបង្រៀន ÷

- ដោយផ្តើមចេញពីទស្សនៈវិស័យវិទ្យាសាស្ត្រ
- ថាមិនអាចចាត់ទុកជាវិទ្យាសាស្ត្រតែឯងបានទេ
- ថាមិនមែនជាចំណុចកំណត់នៃគោលការណ៍ ឬច្បាប់ទេ
- គ្មានវិធីវាស់វែងស្នាដៃនៃការបង្រៀនដោយផ្សារភ្ជាប់នឹងការងារវិទ្យាសាស្ត្រទេ

ប៉ុន្តែក្រោយឆ្នាំ ១៩៦៨ លោក Philip Jackson បានអះអាងថា ព្រឹត្តិការណ៍នៅក្នុងថ្នាក់រៀនកើតឡើងដោយស្ម័គ្រចិត្ត ហើយមានដំណើរការអភិវឌ្ឍដែលគេមិនអាចព្យាករណ៍ទុកបាន ។

ការបង្រៀនពាក់ព័ន្ធទៅនឹងអព្ភន្តរញ្ញាណ ការស្ម័គ្រចិត្ត សិល្បៈគរុកោសល្យដ៏ជំនាញ និង សញ្ចេតនា ដែលជាលក្ខណៈពិសេសមិនអាចចាត់ទុកជាវិទ្យាសាស្ត្របានទេ (Dawes, Eisner, Peterson & Cameaux,1989) ។

**បំណិនក្នុងការបង្រៀនល្អ**

គ្រូបង្រៀនដែលមានសិល្បៈបច្ចេកទេសគរុកោសល្យដ៏ជំនាញក្នុងការបង្រៀនសិស្សអាច ÷

- ប្រើប្រាស់បំណិនដូចគ្នានឹងសិល្បករ និង អ្នកវិទ្យាសាស្ត្រដែរ
- យល់ស៊ីជំរៅទៅលើប្រការណាមួយសំដៅបញ្ចេញនូវពន្លឺថ្មីដែលតាមធម្មតា ការបង្កើតថ្មីរបស់អ្នកវិទ្យាសាស្ត្រធ្វើអោយមានការសំដែងថ្មីរបស់សិល្បករ។ អ្នកវិទ្យាសាស្ត្រ ប្រើប្រាស់អព្ភន្តរញ្ញាណ គំនិតយល់ស៊ីជំរៅ និង គំនិតរវើរវាយ ដើម្បីបង្កើតបានជាទ្រឹស្តីថ្មី ។ គ្រូបង្រៀនអាចប្រើប្រាស់គំនិតថ្មី ដើម្បីត្រិះរិះពិចារណាទៅតាមគំនិតច្នៃប្រឌិត ។ ដូចមុខវិជ្ជាឯកទេសដទៃទៀតដែរ មានពេទ្យ ឬច្បាប់ជាដើម វិទ្យាសាស្ត្រ និង សិល្បៈអាចធ្វើការរួមគ្នាបានក្នុងការបង្កើតនូវការអនុវត្តដ៏មានអត្ថន័យក្នុងវិធីសាស្ត្របង្រៀន និង អប់រំសិស្ស ។

## VI. គ្រូបង្រៀនជាអ្នកធ្វើសេចក្តីសំរេចចិត្ត និង ជាអ្នកដោះស្រាយបញ្ហា

អ្នកអាចទទួលបាននូវបំណិន និង បទពិសោធក្នុងការបង្រៀនល្អ ដោយយល់ស៊ីជំរៅទៅលើ ÷

- របកគំហើញក្នុងការស្រាវជ្រាវថ្មី
- ការបើកទូលាយក្រិតយល់ដឹងទៅនឹងគំនិតថ្មី
- ការចេះត្រិះរិះពិចារណារកហេតុផលអោយបានត្រឹមត្រូវ ។

ពេលដែលអ្នកជាប់ជំពាក់ចិត្តទៅនឹងការបង្រៀនជាវិជ្ជាជីវៈរបស់អ្នក អ្នកគួរតែ ÷

- ត្រូវការបំណិនក្នុងការគិតសំរាប់ពង្រឹងសម្បទារបស់អ្នក
- មានបំណិន និង សម្បទាសំរាប់ជួយអ្នកក្នុងការសំរេចចិត្ត និង ដំណោះស្រាយបញ្ហាប្រកបដោយប្រឌិតញ្ញាណ
- មានវិធីសាស្ត្របង្រៀនដ៏ល្អដែលគួបផ្សំគ្នាដោយលក្ខណៈច្រើនយ៉ាង

- ក្លាយខ្លួនទៅជាអ្នកចេះសំរេចចិត្ត អ្នកចេះសំរបសំរួល អ្នកចេះដោះស្រាយបញ្ហា អ្នកចេះផ្តល់ពត៌មាន និង ជាអ្នកចេះស្រាវជ្រាវ ។ គ្រូឯទៀតចាប់អារម្មណ៏នឹងការបង្រៀនរបស់អ្នក ហើយអ្នកច្បាស់ជាទទួលបានការគាំទ្រពីគ្រូឯទៀតជាមិនខាន ។

## VII. ដំណើរការបដិវត្តនៃគំរិតយល់ដឹង

នៅពេលដែលវិស័យអប់រំមានដំណើរការផ្លាស់ប្តូរហើយ ទាមទារថា តើគ្រូត្រូវបង្រៀនសិស្សយ៉ាងដូចម្តេច នោះចរន្តចិត្តវិទ្យាក៏ផ្លាស់ប្តូរដែរ នោះគឺដំណើរការប្រែប្រួលនៃគំរិតយល់ដឹងនេះឯង ។ ចិត្តវិទ្យាជាមុខជំនាញមួយដ៏ថ្មីស្រឡាង បើធៀបទៅនឹងវិទ្យាសាស្ត្រឯទៀតដូចជា រូបវិទ្យា ឬជីវវិទ្យា ។ មនុស្សរស់នៅលើផែនដីយើងនេះរាប់សតវត្សមកហើយ ប្រាថ្នាចង់ដឹង ចង់ស្គាល់ពីខួរក្បាលមនុស្ស ថាតើវាមានដំណើរការប្រព្រឹត្តទៅយ៉ាងដូចម្តេច ។ ការស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រនេះ បានចាប់ផ្តើមមុនគេបង្អស់នៅប្រទេសអាល្លឺម៉ង់ ក្នុងឆ្នាំ ១៩៧៩ ដោយមានបង្កើតទាំងមន្ទីរពិសោធចិត្តវិទ្យាដំបូងគេផង ។ វិធីដែលគេប្រើប្រាស់ជាដំបូងបង្អស់នៅក្នុងមន្ទីរពិសោធគឺគេបង្គាប់អោយបុគ្គលធ្វើការពិពណ៌នាពីរូបភាពសតិអារម្មណ៏ នៅពេលដែលបុគ្គលនោះកំពុងចូលរួមនៅក្នុងការពិសោធផ្លូវចិត្តប្លែក១ពីគ្នា ។

វិធីស្រាវជ្រាវដ៏ផុសផុលខាងផ្នែកចិត្តវិទ្យាមានអាយុកាលប្រហែល ២៥ ឆ្នាំកន្លងទៅនេះ ។ ក្នុងការស្រាវជ្រាវនេះ ចិត្តវិទូអាមេរិក John Watson សំរេចបានជោគជ័យក្នុងការបញ្ចុះបញ្ចូលក្រុមចិត្តវិទូជាច្រើន ថាតើគេអាចចាត់ទុកចិត្តវិទ្យាជាវិទ្យាសាស្ត្រមួយបានឬទេ ដោយហេតុថា វិទ្យាសាស្ត្រនេះប្រមូលផ្តុំគំនិតទៅលើអាកប្បកិរិយាដែលអាចអោយគេតាមដានសង្កេតបាន ជាជាងរបាយការណ៏ផ្ទាល់មាត់ដែលគេមិនអាចពិនិត្យសង្កេតបានថា តើខួរក្បាលរបស់មនុស្សប្រព្រឹត្តទៅយ៉ាងដូចម្តេច ។ លោក Watson អះអាងថា ÷

- ចិត្តវិទូក៏ដូចជាអ្នកវិទ្យាសាស្ត្រគួរតែសិក្សាពីកម្មវត្ថុនៃបាតុភូត មិនមែនសិក្សាពីប្រធានវិស័យនៃបាតុភូតទេ
- គោលបំណងដំបូងរបស់លោក Watson ក្នុងចិត្តវិទ្យានេះ គឺសំដៅសិក្សាស្រាវជ្រាវទៅលើអាកប្បកិរិយារបស់មនុស្សដែលគេអាចតាមដានសង្កេតបាន ហើយបញ្ហាដែលពាក់ព័ន្ធថា តើខួរក្បាលមានដំណើរការយ៉ាងដូចម្តេចនោះ ត្រូវបានគាត់ច្រានចោលថា មិនមានទំនាក់ទំនងគ្នា នឹង មិនមានលក្ខណៈវិទ្យាសាស្ត្រទេ ។

លោកបានគ្រប់គ្រងវិស័យនេះរហូតដល់ដើមទសវត្សឆ្នាំ ១៩៦០ នៅពេលដែលក្រុមចិត្តវិទូនាំគ្នាត្រឡប់ទៅរកសំនួរជាមូលដ្ឋានដែលចោទសួរថា តើខួរក្បាលមានដំណើរការប្រព្រឹត្តទៅយ៉ាងដូចម្តេចនោះ ។ ក្នុងការប្រកាន់យកសំនួរបែបនេះ ក្រុមចិត្តវិទូបានរកឃើញវិធីសំរាប់ពិនិត្យសង្កេតទៅលើដំណើរការផ្លូវចិត្តរបស់មនុស្សដែលមិនអាចសង្កេតតាមដានបាន ។ ជាពិសេស ក្រុមចិត្តវិទូបែរជាចាប់អារម្មណ៏ទៅនឹងការស្រាវជ្រាវចំពោះដំណើរការយល់ដឹង ជាពាក្យដែលបញ្ជាក់ដល់សកម្មភាពសតិអារម្មណ៏ដូចជា ការប្រុងប្រយ័ត្នស្តាប់ ការយល់ដឹង ការគិត ការចងចាំ ដំណោះស្រាយបញ្ហា ការធ្វើសេចក្តីសំរេចចិត្ត និង គំនិតប្រឌិតញាណ ។ សេចក្តីរកើបបែបនេះ

ងាកទៅរកគោលបំណងរបស់ក្រុមចិត្តវិទូពីមុនដែលត្រូវបានគេបញ្ជាក់ជាទូទៅថា ជាបដិវត្តន៍នៃការយល់ដឹង (លោក Baars 1986) ។ បដិវត្តន៍នេះ សំដៅកំណត់និយមន័យឡើងវិញចំពោះសំណូមពរជាមូលដ្ឋានរបស់ចិត្តវិទ្យា ។

ហេតុផលដ៏សំខាន់ក្នុងការគូសបញ្ជាក់បាននូវបដិវត្តន៍នៃការយល់ដឹងនេះ គឺការងារស្រាវជ្រាវរបស់លោក Jean Piaget ជាចិត្តវិទូជាតិស្វីសដ៏ល្បីល្បាញដែលចង្អុលបង្ហាញថា កុមារប្រើប្រាស់ដំណើរការយល់ដឹងរបស់ខ្លួនដ៏សកម្មសំដៅកសាងអោយបាននូវការយល់ដឹងរបស់គេពីលោក ហើយដំណើរការយល់ដឹងពីដំបូងរបស់គេខុសប្លែកពីគ្នាពីដំណើរការយល់ដឹងពីដំបូងរបស់មនុស្សចាស់ កុមារទទួលលទ្ធកម្មខាងសម្បទានៃការគិតដូចមនុស្សចាស់បានតែដរាបណាដែលកុមារត្រូវបានឆ្លងកាត់ទៅតាមលំដាប់លំដោយនៃដំណាក់ការគិតមួយចំនួនខុសៗគ្នាជាមុនសិន ។

សរុបសេចក្តីមក សន្ទុះអភិវឌ្ឍដ៏ឆាប់រហ័សនៃវិទ្យាសាស្ត្រខាងពត៌មានវិទ្យា បានធ្វើសម្បទានយ៉ាងច្រើនអោយដល់បដិវត្តន៍នៃការយល់ដឹង ។ ក្រុមចិត្តវិទូជាច្រើនបានមើលឃើញ និង យល់ដឹងស្របៗគ្នារវាងករណីដែលថា តើពត៌មានមានដំណើរការប្រព្រឹត្តទៅយ៉ាងដូចម្តេចក្នុងកុំព្យូទ័រ ហើយតើពត៌មានមានដំណើរការប្រព្រឹត្តទៅយ៉ាងដូចម្តេចដែរក្នុងខួរក្បាលមនុស្ស ។ កុំព្យូទ័រទទួលពត៌មានប្រើប្រាស់និមិត្តសញ្ញាយ៉ាងសកម្មរក្សាប្រការនៃពត៌មានទុកក្នុងលំនឹក ហើយផ្តល់ពត៌មានមកវិញ ធ្វើចំណាត់ថ្នាក់ពត៌មានដែលដាក់បញ្ចូលទទួលស្គាល់ការយកលំនាំតាមពត៌មាន និង ធ្វើបាននូវសកម្មភាពឯទៀតៗជាច្រើន គឺជាវិធីដូចគ្នាបេះបិទ ថាតើដំណើរការយល់ដឹងរបស់យើងប្រព្រឹត្តទៅយ៉ាងដូចម្តេច (Neisser, 1976) ។

(នៅមានត)

បណ្ឌិត ចាន់ រដ្ឋសុថា

❄❄❄ ❄❄❄

**អាយុកាលរបស់សត្វខ្លះមានដូចតទៅ ÷**

| | |
|---|---|
| - មេភ្លៀង : ២ ទៅ ៣ ថ្ងៃ | . រៃ : ៣ ទៅ ៤ខែ* |
| - សត្វកណ្តុរ : ៤ឆ្នាំ | . កូនបែ កាំប្រមា : ៥ឆ្នាំ |
| - ទន្សាយព្រៃ : ១០ឆ្នាំ | . ចចក ចៀម : ១៥ឆ្នាំ |
| - ឆ្មា ឆ្កែ : ២០ឆ្នាំ | . គោ ខ្លា : ២៥ឆ្នាំ |
| - ស្វាសាំប៉ង់សេ : ២៥ឆ្នាំ | . ខ្លារខិន ស៊ីរ៉ាប : ៣០ឆ្នាំ |
| - អូដ្ឋ, លា : ៤០ឆ្នាំ | . ពស់ថ្លាន់ : ៧០ឆ្នាំ |
| - អណ្តើក : ២០០ឆ្នាំ | |

* ៣ ទៅ ៤ខែ ជាសភាពវ័យចាស់តែ ១៧ឆ្នាំ ជាជីវិតដង្កូវ




# ថាមពលព្រះអាទិត្យ



ខាងលើ: ការប្រើប្រាស់កញ្ចក់ និង ឡង់ទីដើម្បីប្រមូលផ្តុំកាំរស្មីព្រះអាទិត្យ ត្រូវបានទទួលស្គាល់តាំងពីបុរាណកាល(Antiquité) ។ តាមប្រពៃណី អ្នកប្រាជ្ញដ៏ឆ្នើមនៃស៊ីរ៉ាគូស(១) (Syracuse), អាស៊ីមែត (Archimède) បានកំទេចនាវារ៉ូម៉ាំង ដោយធ្វើអោយឆេះតាមរយៈកាំរស្មីព្រះអាទិត្យដែលបានប្រមូលផ្តុំដោយសារកញ្ចក់ដ៏មហិមា ។

ខាងក្រោម: នៅឆ្នាំ ១៧៧៤ ឡាវ៉ូស៊ីយេ (Lavoisier) បានម៉ៃទៅផលម៉ាស៊ីនថាមពលព្រះអាទិត្យដ៏ពិសេសសំរាប់សម័យកាល ។ ម៉ាស៊ីននេះ ត្រូវបានរចនាឡើងដោយឡង់ទីផតដ៏អស្ចារ្យពីរដែលអាចប្រមូលផ្តុំកាំរស្មីព្រះអាទិត្យធ្វើអោយសីតុណ្ហភាពខ្ពស់អតិបរមា ។

ព្រះអាទិត្យគឺជាប្រភពដើមនៃថាមពល ហើយក្រោមអានុភាពនៃប្រភពនេះ ប្រភពថាមពលដទៃទៀតសឹងទាំងអស់ក៏ត្រូវបានចាប់កកើត ។ ជាក់ស្តែង កាលបើដុតឈើ នោះគឺមនុស្សបញ្ចេញថាមពលព្រះអាទិត្យដែលផ្ទុកនៅក្នុងឈើដោយសារប្រតិកម្មគីមី ។ គេក៏បានដឹងថា ធ្យូងថ្ម និង ប្រេងកាតកើតចេញពីរូបធាតុរុក្ខជាតិដែលមានអត្ថិភាពរាប់រយពាន់ឆ្នាំហើយ ត្រូវបានទទួលចំហេះដ៏ក៏មានថាមពលព្រះអាទិត្យបង្កប់ក្នុងខ្លួនវាដែរ ។

តាមការគណនាចុងក្រោយ ព្រះអាទិត្យបានបញ្ជូនមកអវកាសនូវបរិមាណថាមពលស្មើនឹង ៣៧៨ លានកោដកោដគីឡូវ៉ាត់( ៣៧៨ x ១០$^{២៤}$ ) ។ នេះជាតួលេខដ៏សំបើម តែផែនដីបានទទួលបរិមាណដ៏តិចតួច ១៧០ កោដកោដគីឡូវ៉ាត់( ១៧០ x ១០$^{១៨}$ ) ។ប្រសិនបើយើងចង់មានគំនិតយកកំលាំងនេះមកកសាងមណ្ឌលអគ្គីសនីធំៗនោះ យើងនឹងកសាងបានចំនួន ៥០០ លានមណ្ឌល ។

តាមរយៈការគិតគូស្មានរបស់លោក ផេលិច ប៉ាស្ទ័រ (Félix Pasteur) កាំរស្មីដែលចាំងលើវាលខ្សាច់សាហារ៉ាអាចផ្តល់កំលាំងមួយពាន់ដងលើសកំលាំងផ្គត់ផ្គង់ដោយសារផលិតកម្មធ្យូងពិភពលោក ។ បើគិតអោយដិតដល់ទៅមនុស្សមិនអាចនៅព្រងើយកន្តើយមិនគិតគូរការសិក្សា

(១) ទីក្រុងនៃសហរដ្ឋអាមេរិក (ញូយ៉ក)

ពីការចាប់យក ការប្រមូល ការថ្លៃ និង ការប្រើប្រាស់ថាមពលព្រះអាទិត្យឡើយ ថ្វីបើយើងយល់ថា ប្រភពថាមពលផ្សេងៗទៀត មានល្បឿនយឺត និង ធ្វើអោយទាន់ចិត្តក៏ដោយ ។



នៅទីរហោស្ថាននៃរដ្ឋអារីសូណា មានភូមិគ្រឹះឈ្មោះស្កុតដាល (Scottsdale)[1] ដែលមានឥដ្ឋក្រាលស្រូបពិសេស រៀបលើដំបូលដើម្បីកំដៅទឹកអាងហែលទឹក និង បណ្ដាញបំពង់ខាងក្នុង ។

គេបាននិទានថា អាស៊ីម៉ែត (Archimède) បានយកចិត្តទុកដាក់លើការប្រើប្រាស់ថាមពលព្រះអាទិត្យតាំងពីឆ្នាំ ២១៦ មុនគ.សមកម្លេះ ។ នៅពេលស៊ីគូរ៉ាស (Sycurase) ត្រូវបានហ៊ុំព័ទ្ធដោយសារពួករ៉ូម៉ាំង លោកបានធ្វើអោយនាវាសត្រូវឆេះតាមមធ្យោបាយ"កញ្ចក់ក្ដៅថែស" ពិសេស ។ បទពិសោធរបស់លោក អាស៊ីម៉ែតត្រូវបានលោកអាថាណាក់គីរឆែរ (Athanax Kircher) ចាប់ធ្វើតទៀតនាឆ្នាំ ១៦០០ ដោយបញ្ជាក់ថា គេអាចដុតព្រៃឈើដោយសារកញ្ចក់ក្ដៅថែសរហូតដល់ចំងាយណាមួយ ។

ប្រមាណពាក់កណ្ដាលសតវត្សទី ១៨ ធម្មជាតិវិទូស្វីស លោក ដឺសូស្សួរ (De Saussure) បានកសាងជាលើកដំបូងនូវប្រអប់កំដៅអាចមានសីតុណ្ហភាពលើសពី ១០០°C ។ ក្នុងអំឡុងពេញសតវត្សទី ១៩ និង ដើមឆ្នាំនៃសតវត្សទី ២០ ការសិក្សា និង បទពិសោធជាច្រើនបានតាមដាន និង ឈានដល់ការសំរេចកសាងឧបករណ៍ជាច្រើន (កញ្ចក់. ប្រដាប់បញ្ចាំងពន្លឺជារាងប៉ារ៉ាបូល រឺរាងជាស្វែរ គ្រឿងម៉ាស៊ីនវិលបានអាចតំរង់ទិសយន្តការដែលទទួលយកចំហាយពន្លឺ) កាន់តែមានលទ្ធភាពចាប់យកកាំរស្មីព្រះអាទិត្យ និង បន្ថយការបែកខ្ញែកផ្ការបស់កាំរស្មីនោះ ។ រាល់ការសិក្សាទាំងនោះ បានធ្វើអោយសំរេចគោលដៅទៅលើសមិទ្ធផលគ្រប់វិស័យ ។

នៅអាហ្វ្រិចខាងត្បូង គេឃើញមានជាយូរយារណាស់មកហើយ នៅគ្រឿងម៉ាស៊ីនរាប់រយគ្រឿងដែលប្រើថាមពលព្រះអាទិត្យសំរាប់កំដៅទឹកគេហដ្ឋាន ។ ឧបករណ៍នោះរចនាឡើងដោយមាន ÷

- គ្រឿងសំរាប់ស្រូបចំហាយព្រះអាទិត្យមួយ
- ធុងទឹកចំណុះ ២០០លីត្រមួយ និង
- ទែម៉ូស្តាមួយ

(1) រដ្ឋខាងនិរតីនៃសហរដ្ឋអាមេរិក

ហើយជាទូទៅគេច្រើនដាក់លើដំបូលផ្ទះដោយមានសីតុណ្ហភាពប្រែប្រួលរវាង ៤០ ទៅ ៥០°C ។





ខាងលើ: ក្នុងភូមិភាគដែលមានកំដៅព្រះអាទិត្យច្រើន គេអាចប្រើប្រាស់កំដៅប្រមូលផ្តុំពេញមួយឆ្នាំៗ ដោយសារកញ្ចក់រាងកោង ។ នៅអ៊ីស្រាអែល គេបានស្ថាបនាមណ្ឌលអគ្គីសនីមួយដែលប្រើប្រាស់ដោយថាមពលព្រះអាទិត្យ ។

ខាងក្រោម: គំនូរបំព្រួញនៃសេនេរ៉ាទ័រ អ៊ីស្រាអែល ។ កាំរស្មីកំដៅវត្ថុរាវមួយដែលផ្តល់កំដៅទៅក្នុងអាងធ្វើអោយមានការប្រមូលផ្តុំចំហាយដ៏ខ្លាំង សំរាប់ធ្វើអោយសេនេរ៉ាទ័រដើរ ។ ចំហាយនេះ ធ្លាក់ដល់បំពង់ត្រជាក់ក្លាយជាទឹកត្រឡប់មកអាងកំដៅវិញ ។

ថាមពលព្រះអាទិត្យ ត្រូវបានប្រើប្រាស់ក្នុងការចំរាញ់ទឹកសមុទ្រ និង បង្កលក្ខណៈងាយស្រួលដល់ការបញ្ចូលទឹកក្នុងតំបន់រីងស្ងួតផងដែរ ។

ប៉ុន្តែការប្រើប្រាស់ជាសាមញ្ញបំផុតរបស់ថាមពលព្រះអាទិត្យ គឺការប្រើប្រាស់សំរាប់ចង្ក្រានព្រះអាទិត្យ ដែលជាការចាំបាច់ចំពោះអ្នកស្រុកជាច្រើនប្រទេសដែលមានអំណោយផលខាងធនធានដី តែខ្សត់ខ្សោយខាងប្រភពថាមពល ។ គំរូម៉ាស៊ីនចង្ក្រានព្រះអាទិត្យជាច្រើនជាស្នាដៃរបស់លោក តាស៊ីស៊ី (Tarcici, Alhambra Beyrouth) ហើយស្នាដៃថ្មីៗបំផុតរបស់លោកចំនួន ៦ ត្រូវបានដាក់តាំងពិព័រណ៍នៅខែ វិច្ឆិកា ឆ្នាំ ១៩៤៥ នៅអារីសូណា ។ ចង្ក្រាននេះមានរាងជាបំពង់ធំមួយដែលផ្នែកខាងលើស្ថាបនាឡើងជាបែបបង្ហាបង្អួចបាក់បើកអំពីអាលុយមីនីញ៉ូមចាំង ហើយនៅពេលបើកវាឆ្លុះបញ្ចាំងកាំរស្មីព្រះអាទិត្យទៅលើផ្ទៃរាប ខាងក្នុងមានលាបពណ៌ខ្មៅសំរាប់ស្រូបកាំរស្មី ។ ផ្នែកខាងក្នុងត្រូវបានរុំពាសព័ទ្ធមិនអោយឆ្លងចរន្តកំដៅដោយសារកំទេចកែវវែងៗ ។ ផ្នែកខាងសំប៉ែតសំរាប់ដាក់ចំណីអាហារត្រូវបានបញ្ចូលក្នុងថតចំអិនតាមបញ្ជរស្ថិតខាងក្រោយថតចំអិននោះ ។



ក្នុងការសិក្សាលើអាជីវកម្មជាក់ស្តែងនៃថាមពលព្រះអាទិត្យសព្វថ្ងៃគេប្រើប្រាស់កាំជ្រួចហោះបរមាណូ ដែលអាចបង្កលក្ខណៈទទួលទិន្នន័យពិតប្រាកដទៅលើអាំងតង់ស៊ុតេ និងសមាសភាពរបស់ប្រភេទរស្មី ។

គំរូនេះនឹងមានកំដៅដល់ទៅប្រមាណ១៥០°C ប្រសិនបើសីតុណ្ហភាពព័ទ្ធជុំវិញមានប្រមាណ ២០°C ហើយមានលទ្ធភាពចំអិនបរិមាណចំណីអាហារយ៉ាងសន្ធឹក ។

ការប្រើប្រាស់ថាមពលព្រះអាទិត្យដ៏សំខាន់ម្យ៉ាងទៀត គឺឡរំលាយដែក (Haut fourneau) ដែលត្រូវបានកសាងឡើងដោយអ្នកប្រាជ្ញអាឡឺម៉ង់ លោក រុយដុល ស្ត្រូបែល (Rudolf Straubel) ។ លោកបានស្ថាបនាកញ្ចក់សំរាប់រំលាយកាំរស្មីព្រះអាទិត្យបញ្ចូលគ្នាដែលអាចធ្វើអោយបន្ទះដែកកំរាស់ ៨ ម.ម រលាយក្នុងរវាង ២ រឺ៣ វិនាទី ។

ឡរំលាយដែកម្យ៉ាងទៀត គឺជាស្នាដៃរបស់អ្នកប្រាជ្ញអាមេរិកឈ្មោះ វីលីយ៉ាម ខូន (William Conns) នៃទីក្រុងខាន់សាស់ (Kansas City) ។ លោកសាស្ត្រាចារ្យបែល បានកែលំអឡរំលាយដែកលោក ខូន ខាងលើ ដោយបានបន្ថែមកញ្ចក់រាងកោងសងខាងអំពីអាលុយមីនីញ៉ូមមានវិជ្ឈមាត្រប្រមាណ ៣ ម៉ែត្រដែលអាចទទួលពីសីតុណ្ហភាព ២000°C ។ ឡរំលាយដែករបស់ Valtee Aircraft Corporation de San Diego, USA អាចទទួលសីតុណ្ហភាពរហូតដល់ ៤000°C ។





នៅតាស្កែន (Tachkent) អតីតសហភាពសូវៀត មានស្ថានីយផលិតថាមពលអគ្គីសនីមួយប្រើប្រាស់កញ្ចក់រាងកោងយ៉ាងច្រើន ។ ខាងស្តាំ : ទីតាំងអាជីវកម្មថាមពលព្រះអាទិត្យ ម៉ុងល្វី (Montlouis) នៅពីរ៉េណេ (Pyrénées) កញ្ចក់រាងកោងបានធ្វើអោយកាំរស្មីសំដៅទៅរកកន្លែងតែមួយនៅក្នុងឡព្រះអាទិត្យ ។

មកដល់សព្វថ្ងៃនេះ គេបានធ្វើអាជីវកម្មថាមពលព្រះអាទិត្យដោយផ្ទាល់ ឺដោយប្រយោលអាស្រ័យអានុភាពនៃសីតុណ្ហភាពដែលថាមពលនោះបង្កលក្ខណៈផ្ដល់អោយនៅក្នុងមជ្ឈដ្ឋានកំណត់ណាមួយ ។ ព្រមជាមួយនោះ គេអាចធ្វើអោយម៉ាស៊ីនបូមទឹក ម៉ាស៊ីនប្រើចំហាយ ។ល។ដើរបានដែរ ។



ពិលព្រះអាទិត្យរួមមានសេរី (série) ស្រទាប់ក្រោមនៃស៊ីលិសដាច់ៗគ្នា ។ កាលណាស្រទាប់នោះត្រូវប៉ះគ្នាដោយសារពន្លឺមួយមុខត្រូវទទួលបន្ទុកវិជ្ជមានមួយទៀតជាអវិជ្ជមាន ហើយគេក៏ទទួលចរន្តអគ្គីសនី ។

នៅឆ្នាំ ១៩០១ លោក ហ្វ្រង់ ស៊ូម៉ែន (Frank Shuman) បានកសាងម៉ាស៊ីនប្រើចំហាយដោយថាមពលព្រះអាទិត្យដែលធ្វើអោយស្នប់ពិស្តុងអាចស្រូបទឹកបាន ៣៦00លីត្រក្នុង១នាទី ។

គេក៏បានធ្វើការពិសោធផងដែរ សំដៅការកសាងទូរស័ព្ទដើរដោយមធ្យោបាយថាមពលព្រះអាទិត្យ និង វិទ្យុផ្សាយដោយថាមពល ។

ទីបញ្ចប់ ទីនេះគួររំលឹកដល់គំរោងសាស្ត្រាចារ្យបោម (Baum) នាយកមន្ទីរពិសោធបច្ចេកទេសព្រះអាទិត្យតាស្កែន លោកសុំធ្វើសំណង់មណ្ឌលថាមពលព្រះអាទិត្យមួយមានលទ្ធភាពផ្ដល់ចំហាយចាំបាច់សំរាប់កំដៅទីក្រុងមួយដែលមានប្រជាជនចំនួន ១៧00នាក់ ។ គ្រឿងម៉ាស៊ីននេះ ជាសារវន្តរួមផ្សំដោយកញ្ចក់ដែលមានក្រលាផ្ទៃ

សរុប៤០០០ម$^2$ , កញ្ចក់ទាំងនោះត្រូវបានតំលើងនៅលើរថតូច១ដែលចរាចរនៅលើផ្លូវចំនួន២៣.កំដៅព្រះអាទិត្យដែលបានមកនោះត្រូវប្រមូលនៅលើអាងទឹកធំមួយ ។

នៅពេលថ្មី១នេះ គេបានប្រើប្រាស់គ្រឿងម៉ាស៊ីនថាមពលព្រះអាទិត្យផ្សេងទៀត ដែលរួមផ្សំឡើងដោយថាសស៊ីលីស្យូមតូចមួយដែលមានខ្សែជាច្រើនតភ្ជាប់នឹងអំពូលអគ្គីសនី ហើយត្រូវបានឆេះនៅពេលដែលគេបំបែរមុខស៊ីលីស្យូមទៅរកព្រះអាទិត្យ ។ ម៉ាស៊ីននេះបង្កលក្ខណៈបំលែងថាមពលព្រះអាទិត្យអោយទៅជាថាមពលអគ្គីសនី ។ ម៉ាស៊ីនប្រើដោយស៊ីលីស្យូមត្រូវដើរដោយពន្លឺព្រះអាទិត្យ ទោះបីវាដើរនៅពេលវេលាត្រជាក់ក្ដី តែអោយតែមានព្រះអាទិត្យ ។ ក្នុងឱកាសប៉ុន្មានឆ្នាំចុងក្រោយ១នេះ គេបានគន់គូរការអនុវត្តដែលមានប្រសិទ្ធភាពផ្សេង អំពីថាមពលអគ្គីសនីផ្គត់ផ្គង់ដោយថាមពលព្រះអាទិត្យ ។ អ្នកប្រាជ្ញស្មានថា បន្តិចទៀតមានលទ្ធភាពស្ថាបនាមណ្ឌលមួយអាចផ្គត់ផ្គង់ថាមពលចំនួន ១៥០ Kw ។

ការសិក្សាស្រាវជ្រាវផ្សេងទៀត សំដៅទៅរកអាជីវកម្មថាមពលព្រះអាទិត្យ ដើម្បីបំបែកសមាសភាគផ្សេង១របស់ទឹក ។ រួមមានអ៊ីដ្រូសែនដែលជាឥន្ធនៈបញ្ចេញកំដៅខ្លាំង ។ ដូចនេះមនុស្សមានក្ដីសង្ឃឹមលើប្រភពថាមពលមិនចេះរីងស្ងួតនេះ ។

ចុងក្រោយនេះ គេនឹងប្រើប្រាស់កំដៅព្រះអាទិត្យដើម្បីបង្កើតចំណីអាហារដោយផ្សំពីខ្យល់ និង ទឹក ដោយមិនមានការពឹងអាស្រ័យលើដំណាំ វីកសិកម្មដោយគេនឹងផលិតគ្រឿងបរិភោគក្នុងមន្ទីរពិសោធគីមី ហើយមនុស្សនឹងបើកចំពោះមុខនូវយុគសំបូរបែបឥតព្រំដែន ។

យើងបានដឹងថា ការស្រាវជ្រាវ និង បទពិសោធក្នុងអាជីវកម្មថាមពលព្រះអាទិត្យបានទទួលជោគជ័យដ៏ពិតប្រាកដ តែមានការលំបាកសំខាន់១ច្រើនដែលស្ថិតត្រង់របៀបប្រមូលផ្ដុំ និង ចែកចាយថាមពលនេះ ។

ប្រសិនបើចេះប្រយុទ្ធតទល់នឹងឧបសគ្គនោះបាន មនុស្សអាចមានលទ្ធភាពពិតប្រាកដគ្រប់គ្រងថាមពលមិនចេះរីងស្ងួតដែលអាចជំនួសបានយ៉ាងល្អប្រសើរជាងថាមពលដែលគេបានទទួលពីឥន្ធនៈសព្វថ្ងៃរបស់យើងនោះ ។

ដកស្រង់ និង ប្រែដោយលោក : កែវ យ៉ារ

ប្រភព : *(Encyclopédie pour tous T.6)*

| | | | |
|---|---|---|---|
| - ក្នុងកាលធ្វើពលិកម្ម | ១ | - ក្នុងកាលធ្វើវិវាហៈ | ១ |
| - ក្នុងកាលអន្តរាយ | ១ | - ក្នុងការកំចាត់បង់នូវសត្រូវ | ១ |
| - ក្នុងការដំកើងយស | ១ | - ក្នុងការសង្គ្រោះមិត្រ | ១ |
| - ក្នុងភរិយាជាទីស្រលាញ់ | ១ | - ក្នុងផៅពង្សដែលក្រីក្រ | ១ |

**លោកមិនហៅថា ខុះខ្វាយទ្រព្យទេ**

**ស្រីមិគោបនេសនាគនី ៣**




## ករណីយកិច្ចគ្រូបង្រៀននៅក្រៅសាលារៀន

គ្រូយើងពុំមែនមានតែករណីយកិច្ចបង្រៀន និង អប់រំសិស្សនៅក្នុងសាលារៀនប៉ុណ្ណោះទេ យើងនៅមានករណីយកិច្ចសំខាន់មួយទៀតនៅក្រៅសាលារៀន ។

គ្រូបង្រៀន គឺជាអ្នកដែលមានចិត្តធ្ងន់ អ្នកដែលគួរអោយគេគោរពសរសើរ និង ជាអ្នកបង្ហាត់បង្រៀនចំណេះវិជ្ជា សីលសាស្ត្រផ្សេងៗដល់សិស្ស ។

គ្រូយើងតែងរស់នៅក្បែរសិស្សានុសិស្ស និង ម្ដាយឪពុករបស់ពួកគេ ។ ដូចនេះ គ្រូយើងត្រូវធ្វើយ៉ាងណា ដើម្បីក្លាយខ្លួនទៅជាអ្នកគួរអោយគេគោរពស្រលាញ់រាប់អាន អោយសមនឹងពាក្យថា លោកគ្រូ អ្នកគ្រូ ។

ពាក្យលោកគ្រូ អ្នកគ្រូ គឺជាពាក្យពិរោះពិសាក្រៃលែងនៃសិស្សានុសិស្ស និង អ្នកភូមិស្រុកដែលគ្រូយើងរស់នៅជាមួយ ។ ពួកគាត់ចង់ហៅហើយហៅទៀតដោយគ្មានធុញទ្រាន់ និង ប្រកបដោយទឹកមុខរីករាយ ញញឹម រាក់ទាក់បំផុត ។ ពួកគាត់តែងចង់ជួបនឹងគ្រូយើង ដើម្បីពិភាក្សាបញ្ហាផ្សេងៗដែលគាត់ចង់ដឹង និង ឆ្ងល់ ព្រោះគាត់យល់ច្បាស់ថា គ្រូយើងមានចំណេះដឹង មានទស្សនៈត្រឹមត្រូវ មានចិត្តធ្ងន់ និង មានសីលធម៌ល្អប្រពៃ ។

នៅពេលមានធ្វើបុណ្យទាន រឺពិធីអ្វីមួយ ពួកគាត់តែងអញ្ជើញគ្រូយើងទៅចូលរួមជាភ្ញៀវកិត្តិយសជានិច្ច ។ និយាយរួម គ្រូយើងជាទំនុកចិត្តរបស់សិស្សានុសិស្ស និង ម្ដាយឪពុករបស់ពួកគេ ដូចនេះគ្រូយើងត្រូវបង្ហាញគំរូល្អៗលើគ្រប់ចំនុចដល់ពួកគាត់ ។ ពួកគាត់ទាំងនោះតែងត្រូវការគ្រូយើងជាចាំបាច់បំផុតជាងមន្ត្រីដទៃខ្លះៗទៀត ។ ពួកគាត់តែងប្រៀបផ្ទឹមគ្រូយើងស្មើនឹងបុព្វជិត រឺចៅក្រម ។

### ករណីយកិច្ចគ្រូយើងនៅក្រៅសាលារៀន

ក- គ្រូយើងត្រូវមានចរិយាល្អឥតខ្ចោះលើគ្រប់ចំនុច ព្រោះសិស្សានុសិស្ស និង គ្រួសាររបស់ពួកគេតែងសង្កេត និង ធ្វើតាមជានិច្ចចំពោះគ្រប់សកម្មភាពរបស់គ្រូយើង ។ ប្រសិនបើគ្រូយើងមានប្រពន្ធ រឺប្ដីហើយ យើងត្រូវចេះរួមរស់អោយបានល្អជាមួយគ្រួសារ "គ្រួសារដែលចេះស្រលាញ់ និងរូបរួមគ្នាបានល្អ ពិតជានាំមកនូវជោគជ័យដល់ជីវិតកូនៗ" ។ គ្រូបង្រៀនម្នាក់ដែលកូនគាត់ទៅជាក្មេងខ្វះការអប់រំ (ខិលខូច) បញ្ជាក់អោយឃើញថា គាត់ជាគ្រូបង្រៀនម្នាក់ខ្វះទេពកោសល្យក្នុងការអប់រំកូន ។

ខ- របៀបស្លៀកពាក់របស់គ្រូយើងត្រូវសាមញ្ញ និង សមរម្យ ។ គេសើចចំអកចំពោះគ្រូណាដែលមានសំលៀក

បំពាក់ឆើតឆាយ រឺចង្អៀតចេញរាងវៅមិនសមរម្យ ។ គ្រូបង្រៀន គួរចៀសវាងប្រព្រឹត្តខុសឆ្គងបែបនេះដាច់ខាត ។ គ្រូបង្រៀនដែលនិយមស្លៀកពាក់ខ្ជីខ្ជាបង្កើតអោយមានការខកចិត្តខ្លាំង និង វាយតំលៃពីមហាជន ។ គ្រូបង្រៀនល្អតែងស្លៀកពាក់ទៅតាមការណែនាំរបស់សាលារៀន (ច្បាប់គរុកោសល្យ) គឺសំលៀកបំពាក់សាមញ្ញ និង សមសួន សមជាគ្រូបង្រៀនម្នាក់ឆ្លាត និង វាងវៃ (ភាពសាមញ្ញធ្វើអោយមានសោភ័ណភាព) ។

គ- នៅតាមតំបន់ដែលយើងបង្រៀន គ្រូបង្រៀនត្រូវប្រើសំដីទន់ភ្លន់ សុភាពរាបសា និង មានឫកពាជាអ្នកចេះដឹងដែលគួរអោយគេគោរព និង សរសើរ ។ មិនត្រូវនិយាយកុហក បញ្ឆោត បោកប្រាស បំបែកបំបាក់ គំរាមកំហែង ត្រូវនិយាយពាក្យពិរោះពិសា ផ្អែមល្ហែម ដែលនាំអោយកើតមានទូវមិត្តភាព និង សាមគ្គីភាព ។

ឫកពាក្រអឺតក្រទមរបស់គ្រូបង្រៀន ធ្វើអោយខកចិត្តយ៉ាងខ្លាំងពីមាតាបិតារបស់សិស្ស និង អ្នកដែលគេមានសុភវិនិច្ឆ័យត្រឹមត្រូវ ព្រោះអ្នកទាំងនោះស្អប់ខ្ពើមចំពោះជនដែលវាយឫកពាជាអ្នកធំ ក្រអឺតក្រទម មើលងាយមើលថោក មានគំនិតព្យាបាទ និង ធ្វើអោយខូចប្រយោជន៍ដល់អ្នកដទៃ ។

ប្រសិនបើគ្រូយើងមិនពេញចិត្តនិងទីកន្លែងដែលយើងធ្វើការរាល់ថ្ងៃ ដោយយល់ឃើញថា កន្លែងនេះជាទីជនបទដាច់ស្រយាលពីទីក្រុង រឺជាកន្លែងមួយពុំសមនឹងតំលៃការងាររបស់ខ្លួន អ្នកអប់រំល្អត្រូវចៀសវាងនិយាយ រឺសំដែង ឫកពាបង្ហាញអោយឃើញដល់អ្នកភូមិស្រុក ថាខ្លួនមានការធុញទ្រាន់ក្នុងការរស់នៅជាមួយពួកគាត់ ។

ឃ- គ្រូបង្រៀនត្រូវរាយការណ៍ជូនមាតាបិតាសិស្ស អំពីលទ្ធផលនៃការសិក្សារបស់កូនគាត់រៀងរាល់ខែ ។ គ្រូត្រូវមានការប្រុងប្រយ័ត្នបំផុតចំពោះចំនុចនេះ ។

គ្រូត្រូវសំដែងការស្រលាញ់ចំពោះសិស្សរបស់ខ្លួន ក៏ដូចជាសិស្សទូទៅនៅក្នុងសាលារៀនផងដែរ អោយបានស្មើៗគ្នាមានន័យថា មិនត្រូវស្អប់សិស្សនេះ រឺស្រលាញ់សិស្សនោះ នេះជាអំពើខុសឆ្គងធ្ងន់ធ្ងរបំផុតរបស់គ្រូបង្រៀន ។

ង- គ្រូបង្រៀនត្រូវមានទឹកមុខរួសរាយរាក់ទាក់ជានិច្ចចំពោះសិស្ស និង មាតាបិតារបស់ពួកគេ ពិសេសត្រូវបង្ហាញប្រាប់អំពីសកម្មភាពការងារបង្រៀនដល់ពួកគេ ។

សកម្មភាពគ្រប់បែបយ៉ាងរបស់គ្រូយើង គឺជាការចាប់អារម្មណ៍ សង្កេតតាមដាន និង ធ្វើតាមរបស់សិស្ស និង អ្នកភូមិស្រុក ។ ក្មេងៗក៏នឹងបង្ហាញអោយឃើញអនុភាពខាងផ្លូវកាយ វាចាចិត្ត តាមអំពើរបស់គ្រូ ម្ដាយឪពុក មនុស្សចាស់ មិត្តភក្ដិ និង អ្នកដទៃផងដែរ ។ មេរៀនចិត្តវិទ្យាបានលើកឡើងថា ក្មេងជាអ្នកចូលចិត្តត្រាប់ (L'enfant est imitateur) ។

ឆ- សកម្មភាពក្នុងសង្គម : គ្រូបង្រៀនជាប្រជាពលរដ្ឋម្នាក់ មានសិទ្ធិគ្រប់បែបយ៉ាងដូចជា ប្រជាពលរដ្ឋទូទៅ និង ត្រូវគោរពសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល និង លក្ខន្តិកៈដោយឡែកសំរាប់គំរិតបឋមសិក្សាជីវៈរបស់ខ្លួន លក្ខន្តិកៈគ្រូបង្រៀន លក្ខន្តិកៈគ្រូបង្រៀនគំរិតមូលដ្ឋាន លក្ខន្តិកៈសាស្ត្រាចារ្យ និង ក្រមសីលធមិរបស់ក្រសួងអប់រំ ។

ហ៊ឹម សំណុំ និវត្តជន (អតីតសាស្ត្រាចារ្យ)

៙៙៙៚៚៚

# កំណើតនៃការអប់រំសីលធម៌(ត)

## (ខ្លឹមសារនៃកម្មវិធីអប់រំសីលធម៌សិស្សបឋមសិក្សា ក្នុងសម័យអាណានិគមនិយមបារាំង ឆ្នាំ ១៨៦៣_១៩៥៣)

ប្រទេសកម្ពុជាបានទទួលការគ្រប់គ្រងពីរបបបារាំង (១៨៦៣-១៩៥៣) ។ ក្នុងសម័យនេះ អ្វីៗទាំងអស់របស់ប្រជាជនខ្មែរត្រូវមានការផ្លាស់ប្ដូរជាបន្តបន្ទាប់ ពោលគឺចាប់ពីពាក់កណ្ដាលសតវត្សទី ១៩ មក ស្រុកខ្មែរបានស្ថិតនៅក្រោមរបបអាណានិគមនិយមបារាំង ។ ក្នុងនោះវិស័យអប់រំក៏មានការប្រែប្រួលគួរអោយកត់សំគាល់ ។ សាលារៀនវត្តបែបប្រពៃណីសំរាប់អប់រំកុមារតាំងពីសម័យបុរាណមកនោះ ក៏បានបន្តដំណើរទៅមុខមិនបានដូចដើមឡើយ ។ ចំណែកឯអាជ្ញាធរបារាំង ក៏ចាប់ផ្ដើមបង្កើតសាលាទំនើបអោយដំណើរ ទន្ទឹមគ្នានឹងសាលាវត្តដែរ ដោយចំលងមួយផ្នែកធំតាមបែបសាលារៀននៅប្រទេសបារាំង ពោលគឺចំលងទាំងវិស័យគរុកោសល្យ កម្មវិធីសិក្សា ភាសា អក្សរសាស្ត្រ និង វប្បធម៌ ។ល។ ម្យ៉ាងទៀតដោយអាជ្ញាធរបារាំងបានប្រកាសជ្រើសរើសមន្ត្រីតូចៗ ដើម្បីធ្វើការបំរើការរដ្ឋាភិបាលបារាំង ជាពិសេសអ្នកបកប្រែភាសាបារាំង-ខ្មែរ និង បកប្រែភាសាខ្មែរ-បារាំង ដែលគោលបំណងធំរបស់រដ្ឋាភិបាលបារាំង ក៏ចង់អោយវប្បធម៌ អរិយធម៌របស់គេគ្របដណ្ដប់លើវប្បធម៌ អរិយធម៌ដ៏ល្អរបស់ខ្មែរ ។

គួរចងចាំដែរថា ក្នុងឆ្នាំ ១៨៦៨ សាលាបឋមសិក្សាជាផ្លូវការត្រូវបានបង្កើតឡើងដោយព្រះបាទនរោត្តម ដើម្បីបង្រៀនបុត្រាបុត្រី និង កូនសេនាបតីដែលមានលោក ក្រារាម៉ង់ ជាគ្រូនៅទីនោះ ។ សាលានេះស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងសិក្សាធិការ និង អប់រំ ។ សាលាបឋមសិក្សាផ្លូវការ ត្រូវបានបែងចែកជា ២ ផ្នែកគឺ :

### ១_ សាលាបឋមសិក្សាជាន់ដំបូងតាមវត្ត

យោងតាមអនុក្រឹត្យចុះថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ១៩២៤ បានកំណត់អោយបែងចែកសាលានេះជា ៣ ករិត ។ សិស្សចាប់ផ្ដើមចូលរៀននៅអាយុ ៧-៩ឆ្នាំ គេឈប់សំរាកនៅថ្ងៃបុណ្យទាន ឬថ្ងៃសីល ។ តាមស្មារតីអនុក្រឹត្យ គេចែកសាលានេះជា ៣ ករិត ហើយរៀនរយៈពេល ៣ ឆ្នាំ ។

- ថ្នាក់កុមារដ្ឋានចូលរៀនអាយុ ៧ឆ្នាំ
- ថ្នាក់បរិវច្ឆណដ្ឋានចូលរៀនអាយុ ៨ឆ្នាំ
- ថ្នាក់អាទិកដ្ឋានចូលរៀនអាយុ ៩ឆ្នាំ

### ២_ សាលាបឋមសិក្សាជាន់ដំបូងបារាំង_ខ្មែរ

សាលារៀននេះ សិស្សទាំងពីរភេទចូលរៀននៅអាយុ ៧ ឬ៨ឆ្នាំ រៀនមានរយៈពេល ៣ ឆ្នាំ ហើយចែកជា ៣ ករិតដូចសាលាបឋមសិក្សាជាន់ដំបូងតាមវត្តដែរ ។ តែខុសគ្នាត្រង់គេបញ្ចូលភាសាបារាំងបន្ថែមក្នុងកម្មវិធីសិក្សា ។ ក្នុងមួយសប្ដាហ៍ គ្រូបង្រៀន ៥ថ្ងៃ ក្នុងមួយថ្ងៃគេរៀនពីរពេល គឺព្រឹក និង ល្ងាច ។

### ៣_ កម្មវិធីសិក្សាសីលធម៌នៅសាលាបឋមសិក្សាទាំង ២

កម្មវិធីសិក្សាអប់រំសីលធម៌នៅសាលាបឋមសិក្សា ត្រូវបានគេរៀបចំនៅឆ្នាំ ១៩០២ និង កែទំរង់នៅឆ្នាំ ១៩២៦. ១៩៣៤ និង នៅឆ្នាំ ១៩៣៨ ។

ការបង្រៀនសីលធម៌ជាចំណុចមូលដ្ឋានគ្រឹះក្នុងវិស័យអប់រំ ។ អត្ថប្រយោជន៍នៃមុខវិជ្ជានេះ មានលក្ខណៈសំខាន់ណាស់ដែលត្រូវគេចាត់ទុកថា ជាកំពូលនៃកម្មវិធីសិក្សា ។ គំនិតយល់ដឹងផ្នែកសីលធម៌ គឺជាក្បួនច្បាប់នៃកិរិយាមារយាទរបស់បុគ្គលម្នាក់ៗក្នុងសង្គម ។ នៅពេលដែលសីលធម៌បានស្រុតចុះ ពេលនោះចំណងទាក់ទងទាំងអស់ក្នុងសង្គមត្រូវបានបាត់បង់តម្លៃ ។

ក្បួនច្បាប់សីលធម៌ អាចខុសប្លែកគ្នាពីសញ្ជាតិមួយទៅសញ្ជាតិមួយទៀត ។ ចំពោះសញ្ជាតិតែមួយ សីលធម៌សង្គមអាចប្រែប្រួលបាន កាលណាសីលធម៌នៃសង្គមនោះមានការអភិវឌ្ឍ ។ ការអប់រំសីលធម៌ចំពោះកុមារនៅសាលារៀន គឺឈរលើមូលដ្ឋាននៃបទពិសោធ និង ការប្រតិបត្តិជាក់ស្តែង ហើយមិនពឹងផ្អែកលើទ្រឹស្តីក្នុងសាលារៀនទាំងស្រុងនោះទេ ។

ការអប់រំសីលធម៌ដល់សិស្សនៅក្នុងសាលារៀន អាចមិនបានសំរេចទៅតាមសំណូមពរ ប្រសិនបើគ្រូបង្រៀនមិនយល់ពីបទពិសោធ និង ការអនុវត្តក្នុងសង្គមជាក់ស្តែង ហើយគ្រូមិនបានអោយសិស្សពិភាក្សាវែកញែកអោយច្បាស់លាស់ពីអ្វីដែលជាទង្វើល្អ និង អ្វីជាទង្វើអាក្រក់ក្នុងសង្គម ឬគ្រូមិនបានបណ្តុះដល់សិស្សនូវបញ្ញត្តិ ឬបញ្ញាដ៏ភ្លឺស្វាងចំពោះអាកប្បកិរិយាប្រកបដោយសីលធម៌ក្នុងសង្គម ។ គ្រូត្រូវតែណែនាំសិស្សអោយស្វែងយល់ដឹងដោយខ្លួនឯងថាការងារសេដ្ឋកិច្ច សណ្តាប់ធ្នាប់ ភាពទៀងត្រង់ អត្ថប្រយោជន៍នៃការសិក្សាដែលឈានដល់ដំណាក់ចុងក្រោយ គឺដំណាក់អភិវឌ្ឍនៃគុណធម៌ និង មនសិការ ហើយនិងផ្តល់នូវគុណបំណាច់ដ៏មហិមាសំរាប់អនាគតខ្លួនឯង ។

ការសិក្សា និង ការអប់រំសីលធម៌ដល់សិស្សបឋមសិក្សាអាចមានលក្ខណៈគ្រប់គ្រាន់ទៅបាន លុះណាតែត្រូវចេះទំលាប់អោយសិស្សអនុវត្តនូវទង្វើល្អ និង ចៀសវាងបាននូវទង្វើអាក្រក់ក្នុងសង្គម ក្នុងសាលារៀន ។ ទង្វើអាក្រក់នឹងត្រូវគេចាត់ទុកថា ជាទង្វើខ្វះមនសិការ ខ្វះសីលធម៌ និង ត្រូវគេរិះគន់ ។

ដូចនេះ កម្មវិធីសិក្សាសីលធម៌ក្នុងសាលារៀនសំដៅបណ្តុះអោយបានទង្វើល្អ ទំលាប់ល្អ អាកប្បកិរិយាល្អដល់កុមារ ។ អំពើ ឬទង្វើអាក្រក់ក្នុងមជ្ឈដ្ឋានរស់នៅទាំង ៣ របស់កុមារ( គ្រួសារ សាលារៀន និង សង្គម) គ្រូត្រូវតែជំរុញអោយសិស្សចេះចៀសវាងចេះប្រឆាំង និង ចេះទិតៀនគ្រប់ពេលវេលា ។

ការអប់រំសីលធម៌ក្នុងថ្នាក់បឋមសិក្សាសំដៅអោយសិស្សចេះជួយគ្រប់គ្រងដោយខ្លួនឯង ចេះប្រកាន់យកនូវអាកប្បកិរិយាអហិង្សាក្នុងសង្គម ពោលគឺបណ្តុះបណ្តាលដល់សិស្សនូវបុគ្គលិកលក្ខណៈមួយដែលអាចអោយសិស្សចេះសំរបសំរួលខ្លួននៅក្នុងសង្គម ហើយគ្រូត្រូវចេះទំលាប់សិស្សអោយប្រកាន់យកនូវអាកប្បកិរិយាសីលធម៌ដោយខ្លួនឯងក្នុងមជ្ឈដ្ឋានទាំង ៣ ។

នៅដើមសតវត្សទី ២០ សាលាបឋមសិក្សាអង់គ្លេសបានយកចិត្តយ៉ាងខ្លាំងចំពោះកម្មវិធីសិក្សាអប់រំសីលធម៌ដល់កុមារ ដូចជាទំលាប់សិស្សអោយក្រោកពីដំណេកមកសាលារៀនអោយទាន់ពេល មានសញ្ចេតនាទទួលខុសត្រូវលើកិច្ចការ ឬភារកិច្ចដែលខ្លួនត្រូវធ្វើ អោយមានជំរើសរវាងអំពើល្អ និងអំពើអាក្រក់ ចេះគោរពកោតខ្លាចគ្រូ ចេះគោរពចាស់ព្រឹទ្ធាចារ្យ ចៀសវាងការនិយាយកុហក ការខ្ជិលច្រអូស បើគេហ៊ានធ្វើអំពើអាក្រក់ គេត្រូវទទួលទោសកំហុស ឬផលវិបាកលើទង្វើរបស់គេ ។

មជ្ឈដ្ឋានសង្គមជុំវិញខ្លួនសិស្សសព្វថ្ងៃ ជាកត្តាដែលជះឥទ្ធិពលខ្លាំងជាងគេបង្អស់ចំពោះសីលធម៌របស់កុមារ ។

ទង្វើអសីលធម៌ដែលកើតមានឡើងក្នុងមជ្ឈដ្ឋានសង្គមនៅចំពោះមុខកុមារ ងាយធ្វើអោយកុមារឆាប់ចាប់អារម្មណ៍ និងពិចារណាណាស់ ។ និន្នាការនៃការគ្រាប់តាម តាមបែបអមនសិការចំពោះទង្វើបែបណាមួយនោះ វាជះឥទ្ធិពលខ្លាំងណាស់ក្នុងសតិអារម្មណ៍កុមារ។ ទង្វើរបស់មនុស្សធំ ឬអ្នកស្រករវ័យ ងាយនឹងបណ្ដុះបាននៅក្នុងគំនិតរបស់កុមារ ។ គ្រួសារ និង សាលារៀន ត្រូវអប់រំកុមារអោយចេះវាយតំលៃខ្ពស់ចំពោះទង្វើល្អ និង ចេះរិះគន់ចំពោះទង្វើដ៏ថោកទាបក្នុងសង្គម ។ ឪពុកម្ដាយ ត្រូវជួយបណ្ដុះបញ្ញាញាណ ស្មារតីដល់កុមារជាកូន អោយមានវិជ្ជិចក្នុងការប្រកាន់នូវអាកប្បកិរិយាល្អក្នុងសង្គមនៅចំពោះមុខមហាជននានា ។ ការសំដែងទង្វើអសីលធម៌ខ្លះៗក្នុងសង្គម តាមរយៈកាលវិភាគសិក្សាសីលធម៌នៅក្នុងសាលារៀន ក៏ដូចជារូបភាពមួយដ៏សំខាន់ណាស់ដែររបស់គ្រូ ។

ប្រពៃណី សាសនា និង ការអប់រំសីលធម៌ ត្រូវផ្សារភ្ជាប់គ្នាយ៉ាងជិតស្និទ្ធនៅប្រទេសឥណ្ឌាក្នុងសម័យបុរាណក៏ដូចជាបច្ចុប្បន្នកាលដែរ ។ គេអប់រំសីលធម៌ដល់កុមារបឋមសិក្សាដោយផ្សារភ្ជាប់ទៅនឹងប្រពៃណីសាសនា ។ ការអប់រំសីលធម៌បែបនេះ មានភាពងាយស្រួលក្នុងការណែនាំកុមារអោយយល់ពីការចេះអនុវត្តតាមគោលការណ៍សីលធម៌ក្នុងគ្រួសារ សង្គម និង ក្នុងសាលារៀន ។

ការអប់រំសីលធម៌ដល់សិស្សបឋមសិក្សា ត្រូវសំរបសំរួលទៅតាមតំរូវការសញ្ចេតនា និង ចំណង់ចំណូលចិត្តរបស់សិស្សក្នុងសង្គម គឺការអប់រំភក្ដីភាពចំពោះផលប្រយោជន៍សមូហភាព ការគោរពសណ្ដាប់ធ្នាប់ និង ទំនៀមទំលាប់ក្នុងសង្គម ការគោរពវិន័យ ការស្ដាប់បង្គាប់ឪពុកម្ដាយ និង គ្រូ ។ ការគោរពមនុស្សចាស់ជាកាតព្វកិច្ចដ៏សំខាន់នៅក្នុងកម្មវិធីអប់រំសីលធម៌ ។

**ក- កម្មវិធីសិក្សាឆ្នាំ ១៩២៦:**

កម្មវិធីសិក្សានេះ ត្រូវបានគេរៀបចំឡើងតាមសេចក្ដីប្រកាសចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩២៦ មានឈ្មោះថា "ធម្មក្រិត្យា" សំរាប់សាលាបឋមសិក្សាបំពេញវិជ្ជានៅស្រុកខ្មែរ ពោលគឺសំរាប់ថ្នាក់កុមារដ្ឋាន បរិវេច្ឆណដ្ឋាន និងអាទិកដ្ឋាន ។ សៀវភៅនេះមានអត្ថបទអំណាន តែខ្លឹមសាររបស់វាពោរពេញទៅដោយការអប់រំផ្នែកសីលធម៌ សុភាវធម៌ និង ចរិយាធម៌ល្អៗដល់កុមារា កុមារីដែលបានចូលរៀនក្នុងសាលាវត្ត ឬសាលាបារាំង ហើយពួកគេនឹងក្លាយទៅជាអ្នកចេះដឹងក្នុងស្រុកភូមិដែលគេនាំគ្នាហៅថា អន្ទិត ។ តាមសំដីរបស់ព្រឹទ្ធាចារ្យ យ៉ង់ ធី ជាអតីតអធិការបឋមសិក្សាក្នុងសម័យសង្គមរាស្ត្រនិយម បាននិយាយថា "ក្នុងការនិពន្ធសៀវភៅធម្មក្រិត្យានេះ ពួកបារាំង និងអ្នកជំនាញការខ្មែរ បានប្រមែប្រមូលអ្នកចេះដឹង និងអ្នកបង្រៀនជាគ្រហស្ថ និង ព្រះសង្ឃតាមបណ្ដាខេត្តនានា មកចងក្រងរៀបចំទៅតាមតំរូវការអប់រំជាក់ស្ដែងរបស់កុមារនៅតាមឃុំស្រុក វត្ត និង តំបន់" ។ សៀវភៅនេះ មានកំរាស់ ១០៦ទំព័រ និង ៥ជំពូក ពោលគឺ :

- ជំពូកទី ១ : កុមារក្នុងវង្សត្រកូល

គឺតំរូវអោយកុមារស្នេហាចំពោះមាតាបិតា មានកតញ្ញូធម៌ មានទំនុកបំរុងចំពោះម្ដាយឪពុក ចាស់ជរា មានទំនាក់ទំនងល្អរវាងបងប្អូន បងមានភារកិច្ចចិញ្ចឹមប្អូនជំនួសម្ដាយ ប្អូនមានសេចក្ដីស្នេហាស្មោះចំពោះបង បងប្អូនត្រូវតែរស់នៅជួបជុំគ្នាមានសេចក្ដីអាណិតស្រលាញ់ចំពោះជីដូនជីតា ចាស់ជរា ជីដូនជីតាសប្បាយចិត្តនឹងឃើញចៅប្រតិបត្តិល្អ ការប្រព្រឹត្តល្អរបស់កុមារចំពោះមីងមា សាច់សាលោហិត និង ចំពោះបាវបំរើ ។ តួនាទីរបស់កុមារីក្នុងការរៀបចំផ្ទះ

សំបែង និង ក្លាយខ្លួនជាម្តាយដ៏ល្អក្នុងអនាគត ។ល ។

- ជំពូកទី ២ : ភារកិច្ចកុមារក្នុងសាលារៀន

កូនសិស្សប្រព្រឹត្តល្អ សិស្សឧស្សាហ៍រៀនសូត្រនឹងបានមុខក្រសួងថ្កុំថ្កើង សិស្សមានសប្បុរសធម៌ចំពោះអ្នកដទៃ កិច្ចការរបស់សិស្សនៅសាលា កំហឹងនាំអោយអន្តរាយ ការដឹងគុណរបស់សិស្សចំពោះគ្រូ សិស្សត្រូវធ្វើអ្វីធ្វើអោយហើយ សិស្សត្រូវមានចិត្តអំណត់អត់ធន់ មិនខ្ជះខ្ជាយពេលវេលា សិស្សនិយាយច្រើនឥតបានប្រយោជន៍ ស្ងៀមជាងស្រដី អាកប្បកិរិយារបស់សិស្សនៅក្រៅសាលា សិស្សចិត្តស្រាល សិស្សបង្ករឿងនៅក្រៅសាលា និង ក្នុងសាលា ។ល ។

(នៅមានត)

អនុបណ្ឌិត : គួយ សុគាន
មន្ត្រីផ្នែកវិទ្យាសាស្ត្រអប់រំនៃវិទ្យាស្ថានជាតិអប់រំ

## ពាក្យបណ្តៅ

គឺជាពាក្យចំណោទបញ្ឆិតបញ្ឆៀង ប្រៀបប្រដូច ចោទអោយរក អោយស្រាយឈ្មោះអ្វីមួយដូចពាក្យថាៈ "ឯកអង្គទ្រង់នាមឯក ខ្ពស់អនេក ទាបជាងស្មៅ" តើជាអ្វី ? អ្នករកបណ្តៅប្រាប់ថា ភ្នំ (ត្រូវហើយ) ។ យ៉ាងនេះហៅថាបណ្តៅ ឬពាក្យបណ្តៅ ។

ខ្មែរយើងមានពាក្យបណ្តៅច្រើនណាស់ ចាស់ៗពីព្រេងនាយបានបង្កើតទុកអោយក្មេងៗលេងអោយចេះគិត អោយមានយោបល់សម្បូរ អោយមានប្រាជ្ញាឈ្លាសវៃ ។

ពាក្យបណ្តៅភាគច្រើនមានចុងចួន របៀបជាពាក្យកំណាព្យ ជួនកាលជាកំណាព្យក៏មាន។

លោកគ្រូ អ្នកគ្រូអាចបំផុសការលេងបណ្តៅ និង បង្កើតពាក្យបណ្តៅថ្មីៗថែមទៀត តែគួរចៀសវាងពាក្យអាសគ្រាមដែលនាំអោយក្មេងមានគំនិតផ្តេសផ្តាស ប្រាកចាកសីលធម៌ជាដើម ។

ខ្ញុំសុំសាកល្បងជូនកំណាព្យបណ្តៅមួយដូចតទៅ :

"ជីកហើយជីកទៀត ជីកគ្រប់ល្បិចស្ទៀត ជីកព្រោះចង់បាន
គ្មានគិតថ្ងៃយប់ គ្មានឈប់គិតខាន តែពេលជីកបាន
បែរជាបោះចោល។"

តើជាអ្វី ?

(ចំលើយនៅទំព័រ ៣៩)

យស់ អ៊ាង

# ភាសា

## សំនេរក្នុងសម័យខេមរយានកម្ម[១]

កាលពីថ្ងៃទី ១០ ដល់ ១៣ កក្កដា ១៩៦៧ សមាជជាតិលើកទី ២៣ បានសំរេចអោយប្រើភាសាខ្មែរជាទូទៅក្នុងកិច្ចការរដ្ឋបាល និង ការសិក្សា ។ ក្នុងសម័យប្រជុំថ្ងៃទី ១៤ កក្កដា ១៩៦៧ អ្នកទទួលខុសត្រូវខាងអប់រំនៃក្រសួងអប់រំជាតិបានសំរេចអោយអនុវត្តខេមរយានកម្មគ្រប់មុខវិជ្ជានៅមធ្យមសិក្សា នៅថ្នាក់ទី ៦ ចាប់ពីឆ្នាំសិក្សា ១៩៦៧-៦៨ តទៅ ។ នៅថ្ងៃទី ១៨ កញ្ញា ១៩៦៧ ក្រសួងអប់រំជាតិបានចេញប្រកាសលេខ ២២៩៤ ចុះថ្ងៃទី ១៨/៩/៦៧ បញ្ជាអោយអនុវត្តខេមរយានកម្មក្នុងមធ្យមសិក្សាចេញពីថ្នាក់ទី ៦ ចាប់ពីបវេសនកាលសិក្សា ១៩៦៧-៦៨ តទៅ ។

តាមរយៈបំរើបំរាស់ពាក្យខេមរយានកម្មតាំងពីឆ្នាំ ១៩៦៧ រហូតដល់ឆ្នាំ ១៩៧៥ យើងអាចចែករបៀបសរសេរពាក្យខេមរយានកម្មជា ២ ដំណាក់គឺ ÷

- ដំណាក់ទី ១ ចាប់ពីឆ្នាំ ១៩៦៧ ដល់ ១៩៧២
- ដំណាក់ទី ២ ចាប់ពីឆ្នាំ ១៩៧២ ដល់ ១៩៧៥ ។

### ១_ ដំណាក់ទី១

ដំណាក់ទី ១ ជាដំណាក់ដំបូង ផ្តើមការងារនិពន្ធសៀវភៅខេមរយានកម្ម ។ អង្គការខេមរយានកម្មបានជួបប្រទះការលំបាកគ្រប់បែបយ៉ាង ។ នៅពេលនោះ មានតែគណៈកម្មការបច្ចេកទេសតាមមុខវិជ្ជាប៉ុននោះ ដែលបានខិតខំបកប្រែពាក្យគន្លឹះពីភាសាបារាំងអោយបានគ្រប់គ្រាន់តាមតំរូវការនៃមុខវិជ្ជានីមួយៗ ។ ពាក្យគន្លឹះបង្កើតបានហើយគណៈកម្មការផ្ញើត្រង់ទៅគណៈកម្មការវប្បធម៌តែម្តង ។ តាមរយៈទស្សនាវដ្តីខេមរយានកម្មឆ្នាំ ១៩៦៧ ដល់ ១៩៧១ យើងអាចស្រង់ពាក្យខ្លះមកធ្វើជាឧទាហរណ៍បញ្ជាក់សំនេរពាក្យនៅសម័យនោះ ។

#### ក- ពាក្យខ្មែរ

| | | |
|---|---|---|
| ចម្ងាយ (distance) | តម្លៃ (valeur) | បម្រាប់ (donnée) |
| កម្ពស់ (hauteur) | សម្រិត (décanter) | សម្រេះ (reprise) |
| មេចំឡង (vecteur) | ដូច្នេះ (donc) | ប្រឡាយបញ្ចូលទឹក (rigole d'irrigation) |
| ក្សាំ (adapter) | ឫស (racine) | ថ្នេរថយហ្លួងរម្ញើល (point arrière) |
| នាទីអ្នកហ្វឹកហ្វឺន (rôle de formateur) | | មហាហ្គ័តសករាជ (ère musulmane) ។ |

សំនេរពាក្យខាងលើបញ្ជាក់ថា ខេមរយានកម្មពេលនោះ សរសេរពាក្យគន្លឹះទាំងនោះតាមគោលការណ៍របស់វចនានុក្រមសម្តេចសង្ឃ ជួន ណាតបោះពុម្ពលើកទី ៥ ឆ្នាំ ១៩៦៧-៦៨ ។

#### ខ- ពាក្យខ្ចីពីបាលីសំស្ក្រឹត

(១) ឯកសារសំរាប់សិក្សាស្រាវជ្រាវ

ចតុកោណ (quadrilatère) ចតុប្បាទ (quadrupède)
ឆ្អឹងលលាដ៍ក្បាល (os de crâne) របៀបត្បរ (traitement)
គំនរឧស (bûcher) ការអត់ឱន (tolérance)
ការអនុវត្តន៍ (application) ការពិសោធន៍ (expérience) ។

សំនេរពាក្យខាងលើបញ្ជាក់ថា ខេមរយានកម្មពេលនោះ សរសេរពាក្យគន្លឹះទាំងនោះតាមគោលការណ៍របស់វចនានុក្រមសម្ដេចសង្ឃ ជួន ណាត បោះពុម្ពលើកទី ៥ ឆ្នាំ ១៩៦៧-៦៨ (ដូចជាការសរសេរស្រៈពេញតួ ការនិយមទំរង់ "ការ+នាម" ។

### គ- ពាក្យខ្ចីពីបរទេសផ្សេងទៀត

បំពង់ប៊ែរម៉ាន់ (tube Bergman) ពែក្ស (Perse)
បារ៉ូម៉ែត្រ (baromètre) ផលហ្សូល (effet Joule)
ព្រៃហ្គារីក (garrigue) ព្យុះទីហ្វុង (typhon)
ជីហ្វូសហ្វាត (engrais phosphaté) ស្វាលីយេរ (chevalier)
បាល្លុង (ballon) ពិកនិក (pique-nique)
កាតូដ (cathode) អាស៊ីដ (acide)
អាម៉ូនីញ៉ាក់ (ammoniac) អាលុយមីនីញ៉ូម (aluminium)
ទូណឺវីស (tournevis) ។

សំនេរពាក្យខាងលើបញ្ជាក់ថា ខេមរយានកម្មពេលនោះ សរសេរពាក្យគន្លឹះខ្ចីពីបរទេសក្រៅពីបាលីសំស្ក្រឹតតាមគោលការណ៍របស់វចនានុក្រមសម្ដេចសង្ឃ ជួន ណាត បោះពុម្ពលើកទី៥ ឆ្នាំ ១៩៦៧-៦៨ (ដូចជាការសរសេរតាមជាតិសព្ទ ការប្រើអក្សរត្រួតតួ "ហ្គ ហ្ស ហ្វ ស្ត..." ការសរសេរព្យាង្គតំរួតរបៀប "បាល្លុង" ការជ្រើសរើសព្យញ្ជនៈប្រកបតាមតួអក្សរបរទេស (អាស៊ីដ)) ។

## ២_ ដំណាក់ទី ២

ដំណាក់ទី ២ ជាដំណាក់រៀបចំក្បួនខ្នាតសំរាប់សរសេរ ។ ក្នុងដំណាក់នេះ មានគណៈកម្មការពីរកើតឡើងបន្ថែមគឺ គណៈកម្មការអនុម័តពាក្យ គណៈកម្មការចំរុះខាងភាសាខ្មែរ ។ គណៈកម្មការចំរុះសំរេច "គោលប្រែពាក្យ" ទៅអនុវត្តក្នុងការសរសេរពាក្យខេមរយានកម្ម ។ តាមរយៈសទ្ទានុក្រមខេមរយានកម្ម យើងអាចស្រង់ពាក្យខ្លះមកធ្វើជាឧទាហរណ៍បញ្ជាក់ដូចតទៅ :

### ក- ពាក្យខ្មែរ

ចំងាយ (distance) តំលៃ (valeur)
បំរាប់ (donnée) កំពស់ (hauteur)
ស៊ីត (décanter) សំរេះ (reprise) ថ្មេរថយឡាំងរម្លើល (point arrière)
មេចំលង (vecteur) ប្រលាយបញ្ចូលទឹក (rigole d'irrigation)

ដូចនេះ (donc) ផ្សាំ (adapter) រឹស (racine)

តំកល់សីតុណ្ហភាពអោយនៅដដែល (maintenir la température constante)

ចាប់ជើងអោបចង្កេះបោកបញ្ច្រាស (ramassement de jambe et de ceinture à rebours)

នាទីអ្នកវ៉ឹកវ៉ឺន (rôle de formateur) មហាម៉ាត់សករាជ (ère musulmane) ។

ឧទាហរណ៍ខាងលើបង្ហាញអោយឃើញទំនោរថ្មីរបស់អង្គការខេមរយានកម្មក្នុងការសរសេរពាក្យគន្លឹះ ដូចជា :

- សំនេរពាក្យតាមក្បួនព្យាង្គរាយ (ដូចនេះ) តាមក្បួនដំលើ (ំ) (តំលៃ)
- សំនេរពាក្យដោយរក្សាពាក្យរឹសអោយនៅដដែល (ប្រលង)
- សំនេរពាក្យតាមក្បួនមូលភេទ (ផ្សាំ)
- សំនេរពាក្យដោយសំរួល (ឫ > រឹ ឭ > លឺ ឱ > អោ ហ្វ > វ៉ ហ្ម > ម៉ ហ្ល > ល៉ រឹឡ) ។

<u>**កំណត់សំគាល់:**</u> បើយើងពិនិត្យមើលសំនេរពាក្យក្នុងវចនានុក្រមពុទ្ធសាសនបណ្ឌិត យើងនឹងឃើញមានតំរាយខ្លះៗសំរាប់អោយខេមរយានកម្មកែលំអសំនេរពាក្យគន្លឹះរបស់ខ្លួនអោយមានឯកភាព ។

❖ **ព្យាង្គរាយ និង ព្យាង្គតំរួត**

ទោះបីក្បួនក្នុងទំព័រ "គ" នៃវចនានុក្រមពុទ្ធសាសនបណ្ឌិតប្រាប់របៀបសរសេររាយព្យាង្គ និង ត្រួតព្យាង្គក៏ដោយ ក៏យើងនៅតែឃើញពាក្យមួយចំនួនធំសរសេរបានពីរយ៉ាងដែរ ÷

សម្តែង = សំដែង សម្តោះ = សំដោះ សម្តត = សំតត

សម្តុល = សំតុល សម្តោក = សំតោក សម្ទក់ = សំទក់

សម្បក = សំបក សម្ណាដៃ = សំណាដៃ សម្បារ = សំបារ

សម្បុក = សំបុក សម្បូរ = សំបូរ សម្បោរ = សំបោរ

សម្ពាយ = សំពាយ សម្ភោរ = សំភោរ សម្អប់ = សំអប់... ។

❖ **អក្សរ "ឡ" និង "ល"**

ពាក្យពីរព្យាង្គខ្លះដែលមានសូរ(ឡ) អាចសរសេរបានពីរយ៉ាង ដូចជា ÷

ប្រលោះ = ប្រឡោះ ប្រលូក = ប្រឡូក ប្រលូញ = ប្រឡូញ

ប្រលេះ = ប្រឡេះ ប្រលែង = ប្រឡែង ប្រលូស = ប្រឡូស

ប្រលង = ប្រឡង ប្រលង់ = ប្រឡង់ ស្រលូង = ស្រឡូង... ។

❖ **ការសំរួលសំនេរ**

- ស្រះពេញតួ "ឫ" : រឭក = រលឹក រំឭក = រំលឹក
- ស្រះពេញតួ "ឭ" : ឭសាយ = លឺសាយ ឭជ័យ = លឺជ័យ
  ឭជា = លឺជា ឭលាន់ = លឺលាន់
- ស្រះពេញតួ "ឱ ឪ" : ឱត = អោត រឱក = រអោក ឪ ! = អៅ !
- ព្យញ្ជនៈត្រួតតួ "ហ្វ" : ចាងហ្វាង = ចាងវ៉ាង ហ្វេ = វ៉េ
  គាល់ហ្វៅ = គាល់វ៉ៅ

- ព្យញ្ជនៈត្រួតតួ "ហ្ម" : ហ្មត់ចត់ = ម៉ត់ចត់ ហ្មឺន = ម៉ឺន
  ហ្មូត = ម៉ូត ហ្មេ ! = មេ !
- ព្យញ្ជនៈត្រួតតួ "ហ្ល" : ហ្លាក = ឡាក ហ្លាយ = ឡាយ
  ហ្លេវហ្លៃ = ឡេវឡៃ ថៃហ្លាំង = ថៃឡាំង
- ព្យញ្ជនៈត្រួតតួ "ហ្ន" : ហ្នាំង = ណាំង ហ្នាំ ! = ណាំ !
  ហ្ន៎ះ ! = ណ៎ះ !

## ខ- ពាក្យខ្ចីពីបាលីសំស្ក្រឹត

ចតុកោណ (quadrilatère) ចតុបាទ (quadrupède)

ឆ្អឹងលលាដ៍ក្បាល (Os de crâne) បៀវត្ស (traitement)

គំនរអុស (bûcher) ការអត់អោន (tolérance)

ល័ខ (colorant) អនុវត្តន៍ (application)

ពិសោធន៍ (expérience) អូដ្ឋបូកពីរ (chameau)

តំលៃអនុម័ត (valeur adoptée) ភូមិវិទ្យាអនុវត្ត (géographie appliquée)

ឧទ្យានពិសោធ (arboretum) បញ្ញាបញ្ញត្ត (intelligence conceptuelle)

ជញ្ជីងស្វ័យប្រវត្តិ (balance automatique) ដំណាំពិសោធ (culture expérimentale) ។

ឧទាហរណ៍ខាងលើ បង្ហាញអោយឃើញពីទំនោរថ្មីរបស់អង្គការខេមរយានកម្មក្នុងការសរសេរពាក្យគន្លឹះខ្ចីពីបាលីសំស្ក្រឹត តាមជាតិសព្ទដែលដោយ :

- មិនគោរពក្បួនត្រួតព្យញ្ជនៈក្នុងពាក្យសមាសបែបបាលី (ចតុ + កោណ > ចតុកោណ) ។
- សរសេរតាមទីតាំងនាម គុណនាម ក្នុងកន្សោមពាក្យ (បញ្ញត្តិ (ន) បញ្ញាបញ្ញត្ត (ន+គុ)) ។
- ជ្រើសរើសសំនេរពាក្យងាយជាង (បៀវត្ស គ្មាន "រ៍" ទេ) ។
- សំរួលសំនេរពី ឱ ទៅ អោ (ឱន > អោន) ។

**កំណត់សំគាល់:** ក្នុងវចនានុក្រមសម្ដេចសង្ឃ ជួន ណាត មានតំរាយខ្លះសំរាប់អោយខេមរយានកម្មជ្រើសរើសយកមកអនុវត្ត។

### ❖ ព្យាង្គរាយ និង ព្យាង្គតំរួត

ចំពោះពាក្យដែលអាចសរសេរបានពីរយ៉ាង ខេមរយានកម្មជ្រើសយកព្យាង្គរាយ ÷

សម្បា = សំបា សម្បាច់ = សំបាច់ សម្ភី = សំភី សម្រាជ = សំរាជ... ។

### ❖ ការត្រួតតួបទសមាស

ពាក្យខ្លះត្រូវអនុញ្ញាតអោយសរសេរមិនត្រួតតួបាន ÷

ចតុមុខ = ចតុម្មុខ ចតុលោកបាល = ចតុល្លោកបាល

ពុទ្ធបញ្ញត្តិ = ពុទ្ធប្បញ្ញត្តិ នាមបញ្ញត្តិ = នាមប្បញ្ញត្តិ

បឋមបញ្ញត្តិ = បឋមប្បញ្ញត្តិ វោហារបញ្ញត្តិ = វោហារប្បញ្ញត្តិ... ។

### ❖ ពាក្យសរសេរបានពីរយ៉ាង

ចំពោះពាក្យដែលអាចសរសេរបានពីរយ៉ាង ខេមរយានកម្មជ្រើសយកពាក្យណាដែលសរសេរងាយស្រួល ÷

លលា = លលាដ៍ បៀវត្ស = បៀវត្សរ៍ ល័ខ = ល័ក្ខ

លក្ខខណ្ឌ = ល័ក្ខខ័ណ្ឌ សម្ភាស = សម្ភាសន៍... ។

### ❖ នាម និង កិរិយា (វិគុណនាម)

ពាក្យខ្ចីពីបាលីសំស្ក្រឹតខ្លះមានថ្នាក់នាម និង កិរិយាច្បាស់ ។ ខេមរយានកម្មប្រើពាក្យទាំងនោះសំរបតាមទីកន្លែងពាក្យខ្មែរក្នុងកន្សោមពាក្យ ។

*ឧទាហរណ៍* : ចាំពិសោធមើលសិន ។ គេត្រូវពិសោធអោយឃើញពិត ។ គាត់ធ្លាប់មានពិសោធន៍ ។ គាត់ប្រព្រឹត្តសុចរិតត្រឹមត្រូវ ។ អ្នកនុះមានប្រព្រឹត្តិត្រឹមត្រូវ ។

### <u>សង្កេត</u>

ក្នុងទំព័រ ៦៥៨ មានសេចក្តីដូចតទៅ "តាមបែបវេយ្យាករណ៍ថា បើត្រូវការបង្វែរកិរិយាសព្ទខ្លះអោយជានាមសព្ទ ដោយប្រើពាក្យ ការ ក្តី ដំណើរ សេចក្តី មកផ្សំផងនោះគួរផ្សំជាមួយនឹង កិរិយាសព្ទ ថា ប្រព្រឹត្ត ជាការប្រព្រឹត្ត ក្តីប្រព្រឹត្ត ដំណើរប្រព្រឹត្ត សេចក្តីប្រព្រឹត្ត ដូចនេះវិញ" ។

### ❖ ការសំរួលសំនៅ

ចំពោះពាក្យខ្ចីពីបាលីសំស្ក្រឹតខ្លះ វចនានុក្រមអនុគ្រោះអោយសំរួលសំនៅ ÷

- ស្រះពេញតួ "ឧ" : ឧជ្ជល > អុជ = អុច ឧស = អូស
- ស្រះពេញតួ "ឩ" : ឩដ្ឋ = អូដ្ឋ ឩន = អូន
- ស្រះពេញតួ "ឫ" : ឫស្យា = រឹស្យា ឫទ្ធិ = រឹទ្ធិ សំឫទ្ធ = សំរឹទ្ធ
- ស្រះពេញតួ "ឮ" ឮសូរ = អែសូរ ឮ! = អែ!
- ស្រះពេញតួ "ឱ" : ឱ ! = អោ !

ខេមរយានកម្មជ្រើសយកពាក្យផ្តើមដោយ "អ" (អូន) "រ"(រឹទ្ធិ) មកប្រើ ។

(នៅមានត)

សូ មុយឃៀង

❀ ❀ ❀ ❀ ❀ ❀

# គណិតវិទ្យា

## វិធីបូក និង ដក

- ថ្នាក់ទី ៣
- មេរៀនទី : ៦
- សៀវភៅសិស្សទំព័រ ៥៨

**<u>អត្ថបទជំនួយ:</u>**

ម្ចាស់បណ្ណាគារមួយបានសំរេចបញ្ចុះថ្លៃ ៣២៥ រៀល នៅលើមុខសៀវភៅនីមួយៗ ។ ចូរបំពេញតារាង :

| ចំណងជើង | ថ្លៃធម្មតា | ថ្លៃបន្ទាប់ការបញ្ចុះ |
|---|---|---|
| សិក្សាសង្គម | | |
| គណិតវិទ្យា | | |
| ភាសា | | |


១៩៧២៛


១៧០៥៛


២៤៥៣៛

## បច្ចេកទេសប្រមាណវិធីចែក

- ថ្នាក់ទី ៣
- មេរៀនទី ៩
- សៀវភៅសិស្សទំព័រ ៨៧

**<u>អត្ថបទជំនួយ:</u>**

* ចូរបំពេញប័ណ្ណបញ្ជាទំនិញនេះ

| បរិយាយ | បរិមាណ | ថ្លៃឯកតា | ទឹកប្រាក់សរុប | |
|---|---|---|---|---|
| រ៉ាកែត | ៤ | ..................... | ១៨៨០ | រៀល |
| ប្រអប់គ្រាប់ពីងប៉ុង | ៤ | ១៦០ | .................. | រៀល |
| បាល់ | ២ | ..................... | ១៩៦០ | រៀល |
| អាវយឺត | ៧ | .................... | ៨៣៣០ | រៀល |
| ស្រោមរ៉ាកែត | ១ | ២៥០ | .................. | រៀល |
| | សរុបថ្លៃទំនិញបញ្ជា | | .................. | រៀល |
| | ថ្លៃលីសែង | | ១៥០ | រៀល |
| | សរុបទឹកប្រាក់ចំណាយទាំងអស់ | | ១៣ ២១០ | រៀល |

លោកស្រី កែវ សុប្វិទ្ធ សាស្ត្រាចារ្យចិត្តវិទ្យា-អប់រំ
និង អធិការបឋមសិក្សានៅវិទ្យាស្ថានជាតិអប់រំ

# គណិតវិទ្យា

## ចតុកោណ

- ថ្នាក់ទី ៥
- មេរៀនទី ៥ : ចតុកោណ
- សៀវភៅសិស្សទំព័រទី ៤០

**អនុបទជំនួយ:**

លោកគ្រូ អ្នកគ្រូជាទីមេត្រី ដើម្បីបំពេញអោយស្របទៅតាមតំរូវការរបស់សិស្សានុសិស្សនៅថ្នាក់ទី ៥ និង ជួយលោកគ្រូ អ្នកគ្រូក្នុងការរកលំហាត់ដើម្បីបន្ថែមដាក់អោយសិស្ស ខ្ញុំសូមជូនលំហាត់ខ្លះដូចតទៅ :

១- ចូរដាក់ឈ្មោះចតុកោណនីមួយៗខាងក្រោម ÷




* សូមប្រយ័ត្ន រូបអាចមានទីតាំងផ្សេងៗធៀបទៅនឹងក្រឡារបស់សៀវភៅ

**ចំលើយ:** ១ និង ៤ = ការេ ២.៥.៧ = ចតុកោណកែង ៦ = ប្រលេឡូក្រាម ៣ = ចតុកោណស្មើ

*៤ = អាចជាចតុកោណស្មើក៏បាន ប៉ុន្តែជាការេត្រឹមត្រូវជាង ។

---

២- ចូរគូរអង្កត់ ក ខ និង អង្កត់ ខ គ ដូចរូបខាងស្ដាំរួច ÷

ក- ដៅចំណុច ឃ ដើម្បីអោយចតុកោណ កខគឃ ជាប្រលេឡូក្រាម

ខ- ដៅចំណុច ង និង ច ដើម្បីអោយចតុកោណ កខងច ជាការេ ។




**ចំលើយ:** ក ខ គ ឃ ជាប្រលេឡូក្រាម

ក ខ ង ច ជាការេ



៣- ចូរពិនិត្យរូបនេះរួច ÷

ក- ចូរដាក់ឈ្មោះចតុកោណដែលមានអង្កត់ទ្រូងកែងគ្នា ។

ខ- ចូរដាក់ឈ្មោះចតុកោណដែលមានអង្កត់ទ្រូង ឃ ដែលមិនមែនជាចតុកោណកែង ។

គ- ចូរដាក់ឈ្មោះចតុកោណកែង ២ ដែលមានជ្រុងឈម ២ស្មើគ្នា ។




__ចំលើយ:__ ក- ចតុកោណ **កខឃគ**

ខ- ចតុកោណ **កចឆឃ**

គ- ចតុកោណ **កខគឃ** និង **ងចឆឃ**

---

៤- ចូរគូសអង្កត់ **ង ឆ** ដែលមានប្រវែង 4cm ។ ចូរអ្នកសរសេរពីអ្វីដែលអ្នកត្រូវធ្វើដើម្បីគូររូបការេ **ងចឆជ** មួយដែលមានអង្កត់ទ្រូង **ងឆ** ។ ចូរគូររូបនោះ ។ ង———— ឆ 4cm

__ចំលើយ:__




របៀបសង់ការេ **ងចឆជ**

- ខ្ញុំដាក់ចំណុច **ញ** ចំណុចកណ្ដាលនៃអង្កត់ **ងឆ** ដោយប្រើបន្ទាត់ (**ញង** = **ញឆ**= 2cm)
- ខ្ញុំយកកែងមកគូរបន្ទាត់កែងទៅនឹងអង្កត់ **ងឆ** ត្រង់ចំណុច **ញ** ។
- នៅលើបន្ទាត់នេះ ខ្ញុំដៅចំណុច **ច** និង **ជ** ដោយ **ញច** = **ញជ** = 2cm ។
- ខ្ញុំភ្ជាប់ចំណុច **ងចឆជ** ។ ខ្ញុំបានការេ **ងចឆជ** ។

លោកស្រី **ទិត្យ សារឿន**

អធិការបឋមសិក្សា នៅវិទ្យាស្ថានជាតិអប់រំ

* * * * *

**ចំលើយពាក្យបណ្ដាំទំព័រទី ៣១ :**

**"ជូសបន្លា"**

# គំនូរ

## វិធីបង្រៀនគំនូរ(ត)

ដោយលោក : ប៉ាន់ ត្រា

### ផ្ទាំងគុបតែងលំអ

គំនូសកោងមិនគ្រាន់តែមានតួនាទីទូលំទូលាយខាងគូរផ្សំជារូបភាពផ្សេងៗប៉ុណ្ណោះទេ ។ បើយកបន្ទាត់នោះទៅគូររចនាជាផ្ទាំងគុបតែងលំអក្នុងផ្ទៃការេនោះ គេឃើញថា បន្ទាត់នេះអាចផ្ដល់សោភ័ណភាពយ៉ាងល្អប្រសើរទៀត ។

ដូចនេះនៅខាងក្រោមនេះ សុំជូនផ្ទាំងគុបតែងលំអដោយគំនូសកោងខ្លះ ដើម្បីជាឧទាហរណ៍ ។

**ទំហំការេ**

- ទំហំតូចបំផុត ៥ x ៥ ស.ម
- បើធំជាងទំហំខាងលើនេះទៅទៀតនោះជាការប្រសើរ ប៉ុន្តែកុំអោយធំជាង ១០ x ១០ ស.ម



**របៀបគូរ**

ត្រូវធ្វើតាមវិធីសាស្ត្រ គូរផ្ទាំងគុបតែងលំអថ្នាក់ទី ១

**របៀបដាក់ពណ៌**

- ត្រូវណែនាំសិស្សអោយរកពណ៌មកដាក់ឆ្លាស់គ្នា ដើម្បីអោយគំនូរលេចច្បាស់រឹតតែប្រកបដោយសោភ័ណភាពឡើងទៀត ។

**ខ្សែគុបតែងលំអ**

- បើគេយកផ្ទាំងគុបតែងលំអក្នុងផ្ទៃការេខាងលើណាមួយមកគូរតំរៀបបន្តអោយស្មើគ្នាវែងទៅ គេនឹងបានជាខ្សែគុបតែងលំអដ៏មានសោភ័ណភាពគួរអោយគយគន់ ។

ខាងក្រោមនេះ សុំជូនខ្សែគុបតែងលំអដោយយកផ្ទាំងលំអក្នុងនៃការេខាងលើនេះមករចនា ។

(អោយសិស្សដាក់ពណ៌)



ខ្សែតុបតែងលំអក្នុងផ្ទៃការេដោយរូបភាព

ក្រៅអំពីផ្ទាំងតុបតែងលំអដែលរចនាឡើងដោយបន្ទាត់កោងដូចខាងលើនេះ គេអាចយកគំនូរជារូបភាពផ្សេងៗកើតឡើងដោយបន្ទាត់កោងដែលសិស្សបានគូររួចហើយនោះ មករចនាលំអក្នុងផ្ទៃការេទៀត ។

ពិតមែនគំនូរជារូបភាពទាំងនោះសិស្សបានគូររួចហើយមែន ត្រូវអោយសិស្សគូររំលឹកគំនូរដែលត្រូវដាក់ជាប្រធាននោះឡើងវិញ មុននឹងយកមកគូរដាក់ក្នុងផ្ទៃការេ ដើម្បីតំរៀបជាខ្សែ ។

## របៀបគូរខ្សែតុបតែងលំអដោយរូបភាព

មុននឹងរចនាខ្សែតុបតែងលំអដោយរូបភាពណាមួយ ត្រូវយកគំនូររូបភាពនោះមកគូរអោយបានត្រឹមត្រូវក្នុងផ្ទៃការេជាមុនសិន ទើបយកក្រដាសស្តើងមកដាក់ពីលើ ហើយគូរតាមរូបភាពនោះ រួចផ្តិតតំរៀបបន្តគ្នាអោយស្មើវែងទៅ ។

ធ្វើដូច្នេះ ដើម្បីអោយគំនូរជារូបភាពនោះដូចគ្នា ហើយនាំអោយរហ័សទៀតផង ។

**របៀបរំលេចពណ៌**

- បើគំនូររូបភាពពណ៌ខ្ចី ត្រូវដាក់ថាន[១] (Fond) ពណ៌ចាស់ ។
- បើគំនូររូបភាពពណ៌ចាស់ ត្រូវដាក់ថានពណ៌ខ្ចី ។ ដាក់ពណ៌ដូច្នេះទើបគំនូររូបភាពនោះអាចលេចឡើងបានច្បាស់ ។ នៅខាងក្រោមនេះ គឺជាគំនូរឧទាហរណ៍ខ្លះ ÷

(ដាក់ពណ៌)



(១) ផ្ទៃគំនូរ

# បណ្តាំសខ្មែរកវី

(បទពាក្យ ៧)

ជីវិតសត្វលោកកើតមកហើយ ទុក្ខតាមគ្មានស្បើយជាប់អង្គប្រាណ អ្នកមាន អ្នកក្រទាំងប៉ុន្មាន
មច្ចុរាជកត់បានក្នុងក្រាំងខ្មៅ ។

យប់ថ្ងៃចេះតែកន្លងទៅ បន្សល់ទុកនៅភាពសោកសៅ ព្យាធិតាមទារជរាហៅ
លោភៈអោយក្តៅផ្សាក្នុងចិត្ត ។

ពីព្រោះប្រាថ្នាខុសបំណង មិនដូចខ្លួនប៉ងតាមគំនិត បដិឃៈ[១]ដេញតាមក្រោយប្រកិត
បច្ច័យអោយចិត្តកើតទោសៈ ។

មោហៈវង្វេងក្នុងអារម្មណ៍ លាយឡំ និង សំយោជនៈ ចេតសិកដឹកនាំទៅទំលាក់
ឱឃៈ[២]ជំរៅជ្រៅងងឹត ។

ដូច្នេះគួរតែសែនភ័យខ្លាច អង់អាចសិក្សាប្រឹងរិះគិត មើលក្បួនរៀនច្បាប់គ្រាប់បណ្ឌិត
ពោលឥតពាក្យពិតព្រះពុទ្ធផ្តាំ ។

កុំហ៊ាននិយាយភូតកុហក ក្រែងបាបវាឆក់ទៅដេកត្រាំ ក្នុងមូត្រលាមករាប់លានឆ្នាំ
វេទនារងកម្មក្នុងអបាយ ។

បំណាច់បានកើតមកជាមនុស្ស ត្រូវចេះស្គាល់ខុស រាក់ ជ្រៅ ឆ្ងាយ ស្គាល់ធម៌ខ្ពស់ទាបភាពអន្តរាយ
កុំឃ្លានសប្បាយអោយគេទុក្ខ ។

កុំប្រើល្បិចកលកេងប្រវ័ញ្ច កុំរៀនផ្កាលផ្កាញ់មិនមើលមុខ កុំអាងកំបាំងភ្នែកអ្នកស្រុក
គិតតែសំរុករេចញាប់ដៃ ។

កុំអាងអំណាច និង យសសក្តិ កុំអាងសក្ការៈមានតំលៃ កុំអាងលុយឡានទាន់សម័យ
កុំអាងដីថ្លៃលែងស្គាល់គ្នា ។

កុំរៀនពឹងខ្នងកន្លងច្បាប់ កុំរៀនក្បួនយ៉ាប់តាមពាលា កុំល្អខាងក្រៅដូចផ្លែល្វា
កុំក្នុងស្អុយខ្មៅជាខ្មោចងាប់ ។

កុំនិយាយត្រាប់តាមអ្នកខុស យូរទៅធ្លាក់ចុះក្លាយជាធ្លាប់ តំណតទៅជាទំលាប់
ប្រកាន់ខុសខ្ជាប់ធ្វើជាក្បួន ។

កុំយកជីវិតធ្វើជាល្បែង ប្រកួតប្រជែងរឿងគុំគួន សន្សំទោសៈដាក់ក្នុងខ្លួន
ប្រយ័ត្នកពូនកើតជំលោះ ។

(១) សេចក្តីចង្អៀតចិត្ត. (២) អន្លង់

លោក : ឈាត ថេង



## គ្រាមភាសា

គ្រាមភាសា < គ្រាម = ប្រជុំភូមិ ស្រុក ពួក... + ភាសា = ពាក្យសំដី ។ គ្រាមភាសា គឺជាភាសាអ្នកស្រុក សំដីដែលអ្នកស្រុក អ្នកភូមិនីមួយៗនិយាយតាមទំលាប់ ជូនកាលល្បើងពី ÷

- អក្សរដើម ដូចជាថ្ងៃ > ង៉ៃ, ទៅ > តូវ តុះ, មក > ម.ម៉ុះ... ។
- ពាក្យដើម ដូចជាស្លាប់ > ឡាប់, ម្លូរស្លា > លូឡា, សង្ក្រាជ > សង្ក្រាជ... ។

ជាទូទៅ នៅប្រទេសណាក៏ដូចជាប្រទេសណាដែរ គេសង្កេតឃើញមានភាសាប្រភេទនេះ ។ នៅប្រទេសកម្ពុជាក៏មានបែបនោះដែរ ជាក់ស្ដែងដូចមានឧទាហរណ៍ខាងលើស្រាប់ ហើយមិនតែប៉ុណ្ណោះទេ ខេត្ត-ក្រុង តំបន់នានាក្នុងប្រទេសក៏មានគ្រាមភាសាដែរ ឧទាហរណ៍នៅខេត្តស្វាយរៀង ÷

- អ្នកស្រុក អ្នកភូមិមួយនៅឃុំស្វាយចេក ស្រុករំដួល ទំលាប់និយាយកង្កែប > កង្កើប, បាយដំណើប > បាយដំនែប... ។
- ក្នុងទូទាំងខេត្តគេមានទំលាប់ ។

* កំណត់មនុស្សជា ៣ បែបដោយមានបញ្ញត្តិផ្សេងៗពីគ្នា ។

នៅពេលដែលគេប្រើបញ្ញត្តិនីមួយៗ គេបានសំដែងពីលក្ខណៈសម្បត្តិជននោះស្រាប់ ដោយមិនបាច់បន្ថែមគុណនាមលើ "មនុស្ស" ទៀតឡើយ ÷

> ម្រឹសសំដៅលើជនដែលខូចខិល មានបំណងមិនល្អ ចេញចូលលិបលសំលឹងគយគន់ចង់លួចយករបស់អ្វីៗចេញចូលដើរពេលយប់ជ្រៅ ឧទាហរណ៍ : យប់មិញនេះ ឆ្កែព្រុះច្រើនណាស់ ហើយឆ្មែផ្លាខ្លាំងណាស់ ច្បាស់ជាមានម្រឹសម្រាហើយ ។

> ម្នឹសសំដៅលើជនសាមញ្ញធម្មតា គេច្រើនទំលាប់និយាយ "ម្នឹសម្នា" ឧទាហរណ៍ : មានម្នឹសម្នាដើរពាសវាលពាសកាលចេញចូលក្នុងស្រុកភូមិធម្មតា ។

> មនុស្សសំដៅលើជនដែលមានលក្ខណៈសម្បត្តិល្អប្រសើរសក្តិសមនឹងបញ្ញត្តិថា "មនុស្ស < មនុ + ឧស្សាហ៍" ពោលគឺជនដែលចេះបំពេញការងារល្អ ដឹងខុសត្រូវ មានទ្រព្យសម្បត្តិធូរធារ មានពូជ ពង្ស ឧទាហរណ៍ : គេជាមនុស្សម្នាក់គួរយកតំរាប់តាម ហើយជាជនកំរ ។

* ប្រឹងសំដៅនៅស្ងៀមស្ងាត់ មិនដើរចុះដើរឡើង ឧទាហរណ៍ : កុមារនេះមិនចេះប្រឹងសោះ ។ តែនៅពេលធ្វើការងារធ្ងន់ៗជាក្រុមៗដូចជា ការសែងផ្ទះជាដើម គេក៏ពោលថា "ប្រឹង" ឡើង ។

បើយើងពិនិត្យទស្សនៈទំលាប់អ្នកស្រុកប្រើពាក្យនេះយ៉ាងនោះ នោះយើងយល់កាន់តែច្បាស់នូវអត្ថន័យ "ប្រឹង + ប្រែង" ។ វាជាកំលាំងផ្លូវកាយក្នុងការតាំងខ្លួនអោយបាននឹងនរ ខ្ជាប់ខ្ជួនក្នុងពេលប្រកបការងារ រឺក្នុងអង្គប្រជុំ ហើយកំលាំងផ្លូវកាយនេះត្រូវតាំងអោយបានស៊ប់ដែលកុមារ រឺមនុស្សខ្លះមិនអាចទ្រាំទ្រ ទប់ខ្លួនក្នុងរយៈពេលមួយណានោះ ព្រោះតែគេគ្មានឆន្ទៈជាកំលាំងជំរុញ តេប្រើកំលាំងសុទ្ធ ឧទាហរណ៍ : ប្រឹងហូរញើស ។ ជាទូទៅ បញ្ញត្តិនេះ អ្នកស្រុកប្រើសំរាប់បញ្ជាអោយចេះទប់ខ្លួនអោយប្រឹងប្រែងគ្រប់គ្រងខ្លួនអោយបាននឹងនរ មានសណ្ដាប់ធ្នាប់ : "ប្រឹងមើល! នៅអោយនឹង! កុំដើរចុះដើរឡើងពេក... ។

តាមទស្សនៈអ្នកស្រុកមានទំលាប់ខាងលើនេះ យើងអាចសង្កេតឃើញថា ÷

- អ្នកស្រុក អ្នកភូមិយើងមានបំណងប្រាថ្នាចង់បង្កើតពាក្យអោយបានច្រើន ដែលមានអត្ថន័យគ្រប់គ្រាន់ចៀសវាងប្រើ "ពាក្យ ឃ្លា" ដើម្បីកំណត់លក្ខណៈមនុស្សប្រភេទផ្សេងៗគ្នាដូចជា : មនុស្ស ម្រឹស ចោរ ឃាតក បណ្ឌិត... ដោយមិនបាច់យកពាក្យ "មនុស្ស" មកបន្ថែមគុណបទទៀតទេ ។
- នៅលើទឹកដីកម្ពុជា មានអ្នកស្រុកតាំងពីបូរេប្រវត្តិមកម្ល៉េះ ។ ដូចនេះ អ្នកស្រុកច្បាស់ជាមានបញ្ញត្តិសំរាប់សំដែងសំគាល់ប្រភេទសត្វលោកនេះ ហើយចំណែកពាក្យ "មនុស្ស" ជាភាសាបាលីដែលជាភាសានាំចូលនៅសម័យព្រះពុទ្ធសាសនាចូលមកកម្ពុជា ។
- បើពុំដូចនោះទេ ខ្មែរយើងមានទំលាប់ច្នៃប្រឌិតពាក្យនាំចូលទាំងឡាយអោយស្របទស្សនៈរបស់ខ្លួនដែលនិយមប្រើពាក្យឯកព្យាង្គ ឧទាហរណ៍ : មករា > ម្ករ, ធនុ > ធ្នូ, សាមគ្គ > ស្មគ្រ... ។

ម្យ៉ាងទៀត យើងពុំមានក្បួនច្បាស់លាស់សំរាប់ខេមរនីយកម្មពាក្យនាំចូលទេ ។ យើងឃើញមានការសំរបសំរួលច្រើនដូចមានលើកឡើងក្នុងទស្សនាវដ្ដីអប់រំលេខ ២២ ហើយយើងក៏ឃើញក្នុងករណីពាក្យបាលីដែលមានអក្សរផ្ញើជើង "រ" ក្នុងភាសាខ្មែរ កាលបើមានការកែសំរួលនោះ នោះគេច្រើនប្រើជើង "រ" បកតិ > ប្រក្រតី, មត្សវ > ម្រឹត្សូវ...។ ក្នុងខនេះ ពាក្យមនុស្ស > ម្រឹស រឺម្នឹស ។ បើតាមទំលាប់ជាច្រើនមក មនុស្ស > ម្នុស យ៉ាងនេះឯង ។ ប្រការមួយវិញទៀត យើងក៏ឃើញមាន "ា" "ី" "ុ" សំរួលជា "ឹ" ផងដែរ ឧទាហរណ៍ : មត្សវ > ម្រឹត្សូវ, រុក្ខ > ព្រឹក្ស...។

ចំពោះឧទាហរណ៍នៃគ្រាមភាសា "ប្រឹង" យើងក៏នឹកឃើញថា ពាក្យតែងមានការវិវត្តជានិច្ច ។ ក្រៅពីនេះ ខ្មែរយើងចូលចិត្តប្រើបរិវាស័ព្ទទៀតផង ។ ដូចនោះ "ប្រឹង" ទោលបែបនេះ មិនស្រួលស្ដាប់ក៏បន្ថែម "ប្រឹងប្រែង" ដែលអាចមានន័យថា ប្រឹងដោយខ្លួនឯងបែបជាពាក្យគន្លាស់ក៏មាន រឺក៏បន្ថែមពាក្យមួយទៀតដែលមានន័យដូចគ្នា ឧទាហរណ៍ : ត្រលប់វិលវិញ ហាមមិនអោយចូល... ។

យើងសង្ឃឹមថា អក្សរសាស្ត្រខ្មែរចេះតែរីកចំរើនទៅតាមក្បួនខ្នាតណាមួយជាកំណត់ ព្រោះយើងមានរាជបណ្ឌិតសភាហើយ ដោយខិតខំបន្តការងារពីគណៈកម្មការកសាងវចនានុក្រមខ្មែរដែលមានសម្ដេចសង្ឃ ជួន ណាត ជាអគ្គលេខាធិការ និង គណៈកម្មការចំរុះភាសាខ្មែរនៃខេមរយានកម្មដែលមានព្រះភិក្ខុ ប៉ាង ខាត់ ជាប្រធាន ។

កែវ យ៉ារ

# រង្វាស់ខ្មែរបុរាណ

ប្រជាជនខ្មែរយើងជំនាន់ដើម ប្រើប្រាស់ខ្នាតរង្វាស់ផ្សេងៗយកទៅតាមផ្នែកទាំងឡាយនៃរាងកាយរបស់មនុស្ស ។ ដៃត្រូវបានប្រើជាខ្នាតសំរាប់វាស់ច្រើនជាងគេ តែគេក៏នៅមានប្រើជំហរ ជំហាន ទ្រទូង...ផងដែរ ។ ខ្នាតបុរាណខ្មែរនៅមានសេសសល់ប្រើប្រាស់រហូតដល់បច្ចុប្បន្នខ្លះៗដែរ តែជាទូទៅគេនិយមប្រើប្រាស់មាត្រាប្រព័ន្ធ(១) អស់ហើយ ។

មាត្រាប្រព័ន្ធបានចូលមកក្នុងប្រទេសកម្ពុជានៅសម័យអាណានិគមនិយមបារាំង ។ ការផ្លាស់ប្ដូរទំលាប់មួយទូទាំងប្រទេសមិនមែនជាការងាយស្រួលប៉ុន្មានទេ ។ បារាំងបានបង្ខំតាមទំរង់ផ្លូវច្បាប់អោយខ្មែរប្រើប្រាស់មាត្រាប្រព័ន្ធក្នុងជីវភាពប្រចាំថ្ងៃ ។ នៅថ្ងៃទី ១៣ មិថុនា ១៩១៤ អ្នកតំណាងជាន់ខ្ពស់បារាំង (le Résident supérieur) បានចេញក្រឹត្យមួយតំរូវអោយខ្មែរប្រើមាត្រាប្រព័ន្ធនៅទូទាំងប្រទេស ។ បន្តិចក្រោយមក ព្រះករុណាស៊ីសុវត្ថិបានចេញព្រះរាជក្រឹត្យមួយទៀតនៅថ្ងៃទី ២៩ ធ្នូ ១៩១៤ សុំអោយប្រជានុរាស្ត្រទាំងអស់ឈប់ប្រើព្យាម ហត្ថ ចំអាម... បែរមកទទួលប្រើរង្វាស់ជាម៉ែតវិញ ។ ប្រតិកម្ម និង ការប្រែប្រួលមានតិចតួចណាស់ ការផ្លាស់ពុំទទួលបានលទ្ធផលអ្វីឡើយ ។ ប្រហែល ១០ ឆ្នាំក្រោយ ដោយមើលឃើញថាទៅមិនរួច ទើបរាជការអាណានិគមបានចេញសារាចរមួយទៀតនៅថ្ងៃទី ៤ ឧសភា ១៩២៥ ផ្សព្វផ្សាយទៅតាមខេត្តនីមួយៗដាក់កំហិតអោយអាជ្ញាធរបង្ខំអោយប្រជាជនអនុវត្តការប្រើប្រាស់ប្រព័ន្ធថ្មីនេះ ។ នៅតាមទីក្រុងធំៗ បានចាប់ផ្ដើមប្រើម៉ែត បីដូចជារៀនប្រើរបស់បង្កើតថ្មី ឬជាការសន្មតថ្មីមួយនោះកាន់តែច្រើនឡើងៗជាលំដាប់ ។ ខេត្តតូចៗ និងតំបន់ដាច់ស្រយាលឆ្ងាយៗនៅតែបន្តប្រើរង្វាស់បុរាណអស់ពេលដ៏យូរ ។ អ្នកដែលប្រើម៉ែតដំបូងគេ គឺអ្នកលក់កំណាត់សំពត់ ។ តែបន្តិចម្ដងៗ ដោយឃើញភាពត្រឹមត្រូវច្បាស់លាស់នៃមាត្រាប្រព័ន្ធស្របទៅតាមស្តង់ដារអន្តរជាតិ ប្រជាពលរដ្ឋខ្មែរយើងក៏យល់ព្រមល្មមក្នុងការប្រើប្រាស់ម៉ែតច្រើនឡើងៗ ។

រង្វាស់បុរាណយើងរួមមាន ÷

ព្យាម : ប្រវែងមួយកាងដៃ គឺប្រវែងបួនហត្ថ ។ គេហៅមួយកាងផងដែរ ។

លូក : ប្រវែងពីរហត្ថ គិតពីចុងម្រាមដៃដល់ត្រឹមពាក់កណ្ដាលដើមទ្រូង ។

ហត្ថ : ប្រវែងពីរចំអាម ឬកន្លះលូក គឺប្រវែងពីត្រឹមចុងជុំដៃដល់ចុងម្រាមដៃកណ្ដាល ។ ហត្ថខ្នាតគឺជាខ្នាត ជាងឈើក្នុងសម័យបុរាណប្រវែងកន្លះម៉ែត ។

តក់ : ហត្ថក្រពុំ គឺប្រវែងពីត្រឹមកែងដៃទៅដល់ចុងម្រាមដៃក្ដាប់ក្ដោបចូល ។

ចំអាម : ប្រវែងពីត្រឹមចុងមេដៃទៅចុងម្រាមកណ្ដាលញែកតឹងពីគ្នា ( ប្រវែង១២ធ្នាប់) ។

(១) Système métrique = របៀបរង្វាស់រង្វាល់យកម៉ែតជាមាត្រ



# តើលោកគ្រូ អ្នកគ្រូដឹងឬទេថា...

ជនជាតិដែលបានទទួលតំណែងជាអគ្គលេខាធិការអង្គការសហប្រជាជាតិ ( អ.ស.ប.) គឺ ÷

១- ជនជាតិ ន័រវែស លោក ឡាយ ទ្រីតហាល់ដិន ១៩៤៦-១៩៥២ (Lie Trygve Halvden)

២- ជនជាតិ ស៊ុយអែត លោក ដាកហាំម៉ាហ្សុល ១៩៥៣-១៩៦១ (Dag Hammark Jold)

៣- ជនជាតិ ភូមា លោក អ៊ូ ថាន់ ១៩៦១-១៩៧១ (U Thant)

៤- ជនជាតិ អូទ្រីស លោក ខឺតវាល់ដែម ១៩៧២-១៩៨១ (Kurt Waldheim)

៥- ជនជាតិ ប៉េរូ លោក សាវីយេ ប៉េរ៉េដឺគួអេឡា ១៩៨២-១៩៩១ (Javier Pérez de Cuéllar)

៦- ជនជាតិ អេស៊ីប លោក ប៊ូត្រូស ប៊ូត្រូសកាលី ១៩៩២-១៩៩៦ (B. Boutros Ghali)

៧- ជនជាតិ ហ្គាណា លោក កូហ្វីអាន់ណាន់ ចាប់ពី ១៩៩៧ (Kofi Annan)



# វេទិកាស្ត្រី

ហួរ ស៊ី

## សិទ្ធិនារីចំពោះយុត្តិធម៌ព្រហ្មទណ្ឌ

១. បើសិនជាអ្នកត្រូវគេចាប់ខ្លួន អ្នកមានសិទ្ធិ :
- ដឹងអំពីមូលហេតុនៃការចាប់ខ្លួន និងសួររកដីកាចាប់ខ្លួន
- បង្ហាញខ្លួននៅមុខតុលាការ យ៉ាងយូរ៤៨ម៉ោង ក្រោយការចាប់ខ្លួន ។
(ដោយមិនរាប់បញ្ចូលពេលវេលានៃការធ្វើដំណើរទេ)







២. ក្នុងរយៈពេលជាប់ឃុំឃាំងក្នុងពន្ធនាគារ អ្នកមានសិទ្ធិ :
- សុំមើលដីកាឃុំខ្លួន
- នៅក្នុងបន្ទប់សំរាប់នារី
- មិនត្រូវបានគេដាក់ខ្នោះ ឬធ្វើទារុណកម្មលើរាងកាយឡើយ
- អាចជួបគ្រួសារមិត្តភក្ដ្រ និងមេធាវីរបស់អ្នក
- ទទួលបានការពិនិត្យសុខភាព

៣. នៅពេលបើកសវនាការ អ្នកមានសិទ្ធិ :
- សុំអោយការសួរចំលើយធ្វើឡើងនៅចំពោះមុខអាជ្ញាធរពាក់ព័ន្ធ (មេធាវីសាធារណៈ)
- មិនត្រូវបានគេបង្ខំអោយនិយាយអ្វីដែលប្រឆាំងនឹងឆន្ទៈរបស់ខ្លួន







៤. ក្នុងកំឡុងពេលធ្វើការអង្កេត អ្នកមានសិទ្ធិ:
- សុំអោយមន្ត្រីជានារី មកធ្វើការឆែកខ្លួនរបស់អ្នក
- សុំអោយមន្ត្រីជានារី មកធ្វើការឆែកខ្លួនរបស់សាក្សីជានារី
- សុំអោយមន្ត្រីពេទ្យជានារី មកធ្វើការពិនិត្យលើខ្លួនប្រាណរបស់អ្នក

# អនុសញ្ញាលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (CEDAW)

## មាត្រា ៣ : វិធានការនិងបទបញ្ញត្តិច្បាប់ធានាការអភិវឌ្ឍន៍ស្ត្រី






**ព្រះបរមរាជវាំង នៅឆ្នាំ ១៨៨៥**




**ឆ្មាំការពារព្រះបរមរាជវាំង**